(៣៤៧) កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យនូវកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៣៧៥) ហេតុយា ឆ អារម្មណេ តីណិ អវិគតេ ឆ ។

(៣៧៦) នហេតុយា ទ្វេ នអារម្មណេ បញ្ច នអធិបតិយា ឆ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៣៧៧) កុសលោ សាសវោ ធម្មោ កុសលស្ស សាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ សាសវោ ធម្មោ អកុសលស្ស សាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ សាសវោ ធម្មោ អព្យាកតស្ស សាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៣៧៨) ហេតុយា សត្ត អារម្មណេ ឆ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារស្ស ឯវំ វិត្ថារេតព្វំ ។

(៣៧៩) កុសលំ អនាសវំ ធម្មំ បដិច្ច កុសលោ អនាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ អនាសវំ ធម្មំ បដិច្ច អព្យាកតោ អនាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[៣៧៥] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ៩ ។

[៣៧៦] ក្នុងនហេតុប្បច្ច័យ មានវារៈ ២ ក្នុងនអារម្មណប្បច្ច័យ មានវារៈ៥ ក្នុងនអធិបតិប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[៣៧៧] កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាបច្ច័យនៃកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាបច្ច័យនៃអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ដោយហេតុប្បច្ច័យ ។

[៣៧៨] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

[៣៧៩] កុសលធម៌ មិនមានអាសវៈ អាស្រ័យ នូវកុសលធម៌ មិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានអាសវៈ អាស្រ័យ នូវអព្យាកតធម៌ មិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៣៨០) ហេតុយា ទ្វេ អវិគតេ ទ្វេ ។
សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៣៨១) កុសលោ អនាសវោ ធម្មោ កុសលស្ស អនាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ អនាសវោ ធម្មោ អព្យាកតស្ស អនាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៣៨២) អព្យាកតោ អនាសវោ ធម្មោ អព្យាកតស្ស អនាសវស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ អព្យាកតោ អនាសវោ ធម្មោ កុសលស្ស អនាសវស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

(៣៨៣) កុសលោ អនាសវោ ធម្មោ កុសលស្ស អនាសវស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ ។ អព្យាកតោ អនាសវោ ធម្មោ អព្យាកតស្ស អនាសវស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អព្យាកតោ អនាសវោ ធម្មោ អកុសលស្ស អនាសវស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ ។

កុសលត្តិកសាសវទុកៈ

[ ៣៨០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៣៨១ ] កុសលធម៌ មិនមានអាសវៈ ជាបច្ច័យ នៃកុសលធម៌ មិនមានអាសវៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានអាសវៈ ដោយហេតុប្បច្ច័យ ។

[ ៣៨២ ] អព្យាកតធម៌ មិនមានអាសវៈ ជាបច្ច័យ នៃអព្យាកត-ធម៌ មិនមានអាសវៈ ដោយអារម្មណប្បច្ច័យ អព្យាកតធម៌ មិនមានអាសវៈ ជាបច្ច័យ នៃកុសលធម៌ មិនមានអាសវៈ ដោយអារម្មណ-ប្បច្ច័យ ។

[៣៨៣] កុសលធម៌ មិនមានអាសវៈ ជាបច្ច័យ នៃកុសលធម៌ មិនមានអាសវៈ ដោយអធិបតិប្បច្ច័យ ។ អព្យាកតធម៌ មិនមានអា-សវៈ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានអាសវៈ ដោយអធិបតិប្បច្ច័យ អព្យាកតធម៌ មិនមានអាសវៈ ជាបច្ច័យ នៃអកុសលធម៌ មិនមានអា-សវៈ ដោយអធិបតិប្បច្ច័យ ។

(៣៨៤) កុសលោ អនាសវោ ធម្មោ អព្យាកតស្ស អនាសវស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ អព្យាកតោ អនាសវោ ធម្មោ អព្យាកតស្ស អនាសវស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។

(៣៨៥) ហេតុយា ទ្វេ អារម្មណេ ទ្វេ អធិបតិយា តីណិ អនន្តរេ ទ្វេ សមនន្តរេ ទ្វេ សហជាតេ ទ្វេ អញ្ញមញ្ញេ ទ្វេ និស្សយេ ទ្វេ ឧបនិស្សយេ ចត្តារិ អវិគតេ ទ្វេ ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកសាសវទុកំ និដ្ឋិតំ ។

## កុសលត្តិកអាសវសម្បយុត្តទុកំ

(៣៨៦) អកុសលំ អាសវសម្បយុត្តំ ធម្មំ បដិច្ច អកុសលោ អាសវសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៣៨៧) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បញ្ហាវារេបិ សព្វត្ថ ឯកំ ។

[៣៨៤] កុសលធម៌ មិនមានអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានអាសវៈ ដោយអនន្តរប្បច្ច័យ ។ អព្យាកតធម៌ មិនមានអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានអាសវៈ ដោយអនន្តរប្បច្ច័យ ។

[៣៨៥] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

ចប់ កុសលត្តិកសាសវទុកៈ ។

# កុសលត្តិកអាសវសម្បយុត្តទុកៈ

[៣៨៦] អកុសលធម៌ ប្រកបដោយអាសវៈ អាស្រ័យ នូវអកុសលធម៌ ប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៣៨៧] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី សម្បយុត្តវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

## កុសលត្តិកអាសវវិប្បយុត្តទុកំ

(៣៨៨) កុសលំ អាសវវិប្បយុត្តំ ធម្មំ បដិច្ច កុសលោ អាសវវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ អាសវវិប្បយុត្តំ ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ អាសវវិប្បយុត្តំ ធម្មំ បដិច្ច កុសលោ អាសវវិប្បយុត្តោ ច អព្យាកតោ អាសវវិប្បយុត្តោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ អកុសលំ អាសវវិប្បយុត្តំ ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ អាសវវិប្បយុត្តំ ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ អាសវវិប្បយុត្តញ្ច អព្យាកតំ អាសវវិប្បយុត្តញ្ច ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ អាសវវិប្បយុត្តញ្ច អព្យាកតំ អាសវវិប្បយុត្តញ្ច ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៣៨៩) ហេតុយា សត្ត អារម្មណេ ទ្វេ អធិបតិយា សត្ត អវិគតេ សត្ត ។

កុសលត្តិកអាសវសម្បយុត្តទុកៈ

[ ៣៨៨ ] កុសលធម៌ ដែលប្រាសចាកអាសវៈ អាស្រ័យ នូវកុសលធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ដែលប្រាសចាកអាសវៈ អាស្រ័យ នូវអព្យាកតធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ ដែលប្រាសចាកអាសវៈក្តី អព្យាកតធម៌ ដែលប្រាសចាកអាសវៈក្តី អាស្រ័យ នូវកុសលធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកអាសវៈ អាស្រ័យ នូវអកុសលធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកអាសវៈ អាស្រ័យ នូវអព្យាកតធម៌ ដែលប្រាសចាកអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកអាសវៈ អាស្រ័យ នូវកុសលធម៌ ដែលប្រាសចាកអាសវៈផង នូវអព្យាកតធម៌ ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកអាសវៈ អាស្រ័យ នូវអកុសលធម៌ ដែលប្រាសចាកអាសវៈផង នូវអព្យាកតធម៌ ដែលប្រាសចាកអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៣៨៩ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៣៩០) កុសលោ អាសវវិប្បយុត្តោ ធម្មោ កុសលស្ស អាសវវិប្បយុត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ អាសវវិប្បយុត្តោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ អាសវវិប្បយុត្តោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៣៩១) ហេតុយា បញ្ច អារម្មណេ នវ អធិបតិយា បញ្ច អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកអាសវសម្បយុត្តទុកំ និដ្ឋិតំ ។

## កុសលត្តិកអាសវសាសវទុកំ

(៣៩២) អកុសលំ អាសវញ្ចេវ សាសវញ្ច ធម្មំ បដិច្ច អកុសលោ អាសវោចេវ សាសវោច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៣៩៣) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

(៣៩០) កុសលធម៌ ដែលប្រាសចាកអាសវៈ ជាបច្ច័យ នៃកុសលធម៌ ដែលប្រាសចាកអាសវៈ ដោយហេតុប្បច្ច័យ មានវារៈ៣ ។ អកុសលធម៌ ដែលប្រាសចាកអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ដែលប្រាសចាកអាសវៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ដែលប្រាសចាកអាសវៈ ដោយហេតុប្បច្ច័យ ។

(៣៩១) ក្នុងហេតុប្បច្ច័យ មានវារៈ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ៥ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

ចប់ កុសលត្តិកអាសវសម្បយុត្តទុកៈ ។

## កុសលត្តិកអាសវសាសវទុកៈ

(៣៩២) អកុសលធម៌ ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវអកុសលធម៌ ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៣៩៣) ក្នុងហេតុប្បច្ច័យ មានវារៈ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១ ។

កុសលត្តិកអាសវសាសវទុកំ

## សហជាតវារេបិ សម្បយុត្តវារេបិ បញ្ហាវារេបិ

## សព្វត្ថ ឯកំ ។

(៣៩៤) កុសលំ សាសវញ្ចេវនោចអាសវំ ធម្មំ បដិច្ច កុសលោ សាសវោចេវនោចអាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ សាសវញ្ចេវនោចអាសវំ ធម្មំ បដិច្ច អកុសលោ សាសវោចេវនោចអាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ សាសវញ្ចេវនោចអាសវំ ធម្មំ បដិច្ច អព្យាកតោ សាសវោចេវនោចអាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ សាសវញ្ចេវនោចអាសវញ្ច អព្យាកតំ សាសវញ្ចេវនោចអាសវញ្ច ធម្មំ បដិច្ច អព្យាកតោ សាសវោចេវនោចអាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ សាសវញ្ចេវនោចអាសវញ្ច អព្យាកតំ សាសវញ្ចេវនោចអាសវញ្ច ធម្មំ បដិច្ច អព្យាកតោ សាសវោចេវនោចអាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

កុសលត្តិកអាសវសាសវទុកៈ

កុសលប្បច្ច័យទាំងអស់ កុសលសហជាតវារៈក្តី សម្បយុត្តវារៈក្តី

បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

[ ៣៩៤ ] កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ អាស្រ័យ នូវកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ អាស្រ័យ នូវអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ អាស្រ័យ នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ អាស្រ័យ នូវកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈផង នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ អាស្រ័យ នូវអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈផង នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៣៩៥) ហេតុយា ឆ អារម្មណេ តីណិ អធិបតិយា ឆ អវិគតេ ឆ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៣៩៦) កុសលោ សាសវោចេវ ចអាសវោ ធម្មោ កុសលស្ស សាសវស្សចេវ ចអាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ សាសវោចេវនោចអាសវោ ធម្មោ អកុសលស្ស សាសវស្សចេវនោចអាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ សាសវោចេវនោចអាសវោ ធម្មោ អព្យាកតស្ស សាសវស្សចេវនោចអាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៣៩៧) ហេតុយា សត្ត អារម្មណេ ឆ អធិបតិយា ឆ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកអាសវសាសវទុកំ និដ្ឋិតំ ។

(៣៩៥) ក្នុងហេតុប្បច្ច័យ មាន៩វារៈ ក្នុងអារម្មណប្បច្ច័យ មាន៣វារៈ ក្នុងអធិបតិប្បច្ច័យ មាន៩វារៈ ក្នុងអវិគតប្បច្ច័យ មាន៩វារៈ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៣៩៦) កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ ជាបច្ច័យ នៃកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ ដោយហេតុប្បច្ច័យ មាន៣វារៈ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ ជាបច្ច័យ នៃអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈដោយហេតុប្បច្ច័យ មាន៣វារៈ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទាំងមិនមែនជាអាសវៈ ដោយហេតុប្បច្ច័យ ។

(៣៩៧) ក្នុងហេតុប្បច្ច័យ មាន៧វារៈ ក្នុងអារម្មណប្បច្ច័យ មាន៩វារៈ ក្នុងអធិបតិប្បច្ច័យ មាន៩វារៈ ក្នុងអវិគតប្បច្ច័យ មាន១៣វារៈ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

ចប់ កុសលត្តិកអាសវសាសវទុកៈ ។

# កុសលត្តិកអាសវអាសវសម្បយុត្តទុកំ

(៣៩៨) អកុសលំ អាសវញ្ចេវ អាសវសម្បយុត្តញ្ច ធម្មំ បដិច្ច អកុសលោ អាសវោចេវ អាសវសម្បយុត្តោច ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

(៣៩៩) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ សម្បយុត្តវារេបិ បញ្ហាវារេបិ

សព្វត្ថ ឯកំ ។

(៤០០) អកុសលំ អាសវសម្បយុត្តញ្ចេវ នោចអាសវំ ធម្មំ បដិច្ច អកុសលោ អាសវសម្បយុត្តោចេវ នោចអាសវោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

(៤០១) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ សម្បយុត្តវារេបិ បញ្ហាវារេបិ

សព្វត្ថ ឯកំ ។

កុសលត្តិកអាសវអាសវសម្បយុត្តទុកំ និដ្ឋិតំ ។

# កុសលត្តិកអាសវអាសវសម្បយុត្តទុកៈ

(៣៩៨) អកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ អាស្រ័យ នូវអកុសលធម៌ ជាអាសវៈ ទាំងប្រកបដោយអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៣៩៩) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី សម្បយុត្តវារៈក្តី

បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

(៤០០) អកុសលធម៌ ប្រកបដោយអាសវៈ ទាំងមិនមែនជាអាសវៈ អាស្រ័យ នូវអកុសលធម៌ ប្រកបដោយអាសវៈ ទាំងមិនមែនជាអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤០១) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី សម្បយុត្តវារៈក្តី

បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

ចប់ កុសលត្តិកអាសវអាសវសម្បយុត្តទុកៈ ។

## កុសលត្តិកអាសវវិប្បយុត្តសាសវទុកំ

(៤០២) កុសលំ អាសវវិប្បយុត្តំ សាសវំ ធម្មំ បដិច្ច កុសលោ អាសវវិប្បយុត្តោ សាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ អាសវវិប្បយុត្តំ សាសវំ ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ សាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ អាសវវិប្បយុត្តំ សាសវំ ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ សាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ អាសវវិប្បយុត្តំ សាសវញ្ច អព្យាកតំ អាសវវិប្បយុត្តំ សាសវញ្ច ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ សាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ អាសវវិប្បយុត្តំ សាសវញ្ច អព្យាកតំ អាសវវិប្បយុត្តំ សាសវញ្ច ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ សាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤០៣) ហេតុយា សត្ត អារម្មណេ ទ្វេ អវិគតេ សត្ត ។

# កុសលត្តិកអាសវវិប្បយុត្តសាសវទុកៈ

[៤០២] កុសលធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវកុសលធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវអកុសលធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវអព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវកុសលធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង នូវអព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ អាស្រ័យ នូវអកុសលធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង នូវអព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤០៣] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ។

សហជាតវារោបិ សម្បយុត្តវារោបិ

បដិច្ចវារសទិសា ។

(៤០៤) កុសលោ អាសវវិប្បយុត្តោ សាសវោ ធម្មោ កុសលស្ស អាសវវិប្បយុត្តស្ស សាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ អាសវវិប្បយុត្តោ សាសវោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស សាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ អាសវវិប្បយុត្តោ សាសវោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស សាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤០៥) ហេតុយា បញ្ច អារម្មណេ នវ អធិបតិយា ចត្តារិ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៤០៦) កុសលំ អាសវវិប្បយុត្តំ អសាសវំ ធម្មំ បដិច្ច កុសលោ អាសវវិប្បយុត្តោ អសាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ អាសវវិប្បយុត្តំ អសាសវំ ធម្មំ បដិច្ច អព្យាកតោ អាសវវិប្បយុត្តោ អសាសវោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

កុសលត្តិកអាសវវិប្បយុត្តសាសវទុកៈ

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចបដិច្ចវារៈដែរ ។

[៤០៤] កុសលធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាបច្ច័យ នៃកុសលធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រាសចាកអាសវៈ តាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈ ដោយហេតុប្បច្ច័យ ។

[៤០៥] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា

បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

[៤០៦] កុសលធម៌ ប្រាសចាកអាសវៈ តាំងមិនមានអាសវៈ អាស្រ័យ នូវកុសលធម៌ ប្រាសចាកអាសវៈ តាំងមិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ តាំងមិនមានអាសវៈ អាស្រ័យ នូវអព្យាកតធម៌ ប្រាសចាកអាសវៈ តាំងមិនមានអាសវៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤០៧) ហេតុយា ទ្វេ អារម្មណេ ទ្វេ អវិគតេ ទ្វេ ។
សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៤០៨) កុសលោ អាសវវិប្បយុត្តោ អនាសវោ ធម្មោ កុសលស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ អាសវវិប្បយុត្តោ អនាសវោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤០៩) អព្យាកតោ អាសវវិប្បយុត្តោ អនាសវោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ អព្យាកតោ អាសវវិប្បយុត្តោ អនាសវោ ធម្មោ កុសលស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

(៤១០) កុសលោ អាសវវិប្បយុត្តោ អនាសវោ ធម្មោ កុសលស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ ។ អព្យាកតោ

[៤០៧] កុសលហេតុប្បច្ច័យ មានវារៈ ៤ កុសលអារម្មណប្បច្ច័យ មានវារៈ ២ កុសលអធិបតិប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[៤០៨] កុសលធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃកុសលធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយហេតុប្បច្ច័យ ។

[៤០៩] អព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយអារម្មណប្បច្ច័យ អព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃកុសលធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយអារម្មណប្បច្ច័យ ។

[៤១០] កុសលធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃកុសលធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយអធិបតិប្បច្ច័យ ។ អព្យាកតធម៌

អាសវវិប្បយុត្តោ អនាសវោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ អព្យាកតោ អាសវវិប្បយុត្តោ អនាសវោ ធម្មោ កុសលស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស អធិបតិប្បច្ចយេន បច្ចយោ ។

(៤១១) កុសលោ អាសវវិប្បយុត្តោ អនាសវោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។ អព្យាកតោ អាសវវិប្បយុត្តោ អនាសវោ ធម្មោ អព្យាកតស្ស អាសវវិប្បយុត្តស្ស អនាសវស្ស ធម្មស្ស អនន្តរប្បច្ចយេន បច្ចយោ ។

(៤១២) ហេតុយា ទ្វេ អារម្មណេ ទ្វេ អធិបតិយា តីណិ អនន្តរេ ទ្វេ សមនន្តរេ ទ្វេ សហជាតេ ទ្វេ អញ្ញមញ្ញេ ទ្វេ និស្សយេ ទ្វេ ឧបនិស្សយេ ចត្តារិ អវិគតេ ទ្វេ ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកអាសវវិប្បយុត្តសាសវទុកំ និដ្ឋិតំ ។

ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយអធិបតិប្បច្ច័យ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃកុសលធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយអធិបតិប្បច្ច័យ ។

(៤១១) កុសលធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយអនន្តរប្បច្ច័យ ។ អព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ដោយអនន្តរប្បច្ច័យ ។

(៤១២) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសមនន្តរប្បច្ច័យ មានវារៈ ២ ក្នុងសហជាតប្បច្ច័យ មានវារៈ ២ ក្នុងអញ្ញមញ្ញប្បច្ច័យ មានវារៈ ២ ក្នុងនិស្សយប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

ចប់ កុសលត្តិកអាសវវិប្បយុត្តសាសវទុកៈ ។

## កុសលត្តិកឆគោច្ឆកទុកំ

(៤១៣) អកុសលំ សញ្ញោជនំ ធម្មំ បដិច្ច ... អកុសលំ គន្ថំ ... ឱឃំ យោគំ នីវរណំ ... ។ កុសលំ នោបរាមាសំ ធម្មំ បដិច្ច កុសលោ នោបរាមាសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា អាសវគោច្ឆកសទិសំ ។ ទិដ្ឋី បដិច្ច ទិដ្ឋិ ន ឧប្បជ្ជតិ ។

កុសលត្តិកឆគោច្ឆកទុកំ និដ្ឋិតំ ។

## កុសលត្តិកសារម្មណទុកំ

(៤១៤) កុសលំ សារម្មណំ ធម្មំ បដិច្ច កុសលោ សារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ សារម្មណំ ធម្មំ បដិច្ច អកុសលោ សារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ សារម្មណំ ធម្មំ បដិច្ច អព្យាកតោ សារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤១៥) ហេតុយា តីណិ អារម្មណេ តីណិ អវិគតេ តីណិ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

# កុសលត្តិកឆគោច្ឆកទុកៈ

[ ៤១៣ ] អាស្រ័យ នូវអកុសលធម៌ ជាសញ្ញោជនៈ . . . ជាគន្ថ: ជាអកុសល . . . ជាឱឃៈ ជាយោគៈ ជានីវរណៈ . . . ។ កុសលធម៌ មិនមែនជាបរាមាសៈ អាស្រ័យ នូវកុសលធម៌ មិនមែនជាបរាមាសៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ប្រហែលគ្នានឹងអាសវគោច្ឆកៈដែរ ។ ទិដ្ឋិ មិនកើតឡើង ព្រោះអាស្រ័យ នូវទិដ្ឋិទេ ។

ចប់ កុសលត្តិកឆគោច្ឆកទុកៈ ។

# កុសលត្តិកសារម្មណទុកៈ

[ ៤១៤ ] កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ អាស្រ័យ នូវកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ អាស្រ័យ នូវអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ អាស្រ័យ នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៤១៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៤១៦) កុសលោ សារម្មណោ ធម្មោ កុសលស្ស សារម្មណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អកុសលោ សារម្មណោ ធម្មោ អកុសលស្ស សារម្មណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ សារម្មណោ ធម្មោ អព្យាកតស្ស សារម្មណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤១៧) កុសលោ សារម្មណោ ធម្មោ កុសលស្ស សារម្មណស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

(៤១៨) ហេតុយា តីណិ អារម្មណេ នវ អធិបតិយា សត្ត អវិគតេ តីណិ ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៤១៩) អព្យាកតំ អនារម្មណំ ធម្មំ បដិច្ច អព្យាកតោ អនារម្មណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤២០) ហេតុយា ឯកំ អវិគតេ ឯកំ ។

(៤២១) នហេតុយា ឯកំ ។

កុសលត្តិកសារម្មណទុកៈ

[ ៦១៦ ] កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ជាបច្ច័យ នៃកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ដោយហេតុប្បច្ច័យ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ជាបច្ច័យ នៃអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ជាបច្ច័យ នៃអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ដោយហេតុប្បច្ច័យ ។

[ ៦១៧ ] កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ជាបច្ច័យ នៃកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ ដោយអារម្មណប្បច្ច័យ ។

[ ៦១៨ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

[ ៦១៩ ] អព្យាកតធម៌ មិនមានអារម្មណ៍ អាស្រ័យ នូវអព្យាកតធម៌ មិនមានអារម្មណ៍ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦២០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

[ ៦២១ ] ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ។

សហជាតភាគេបិ សម្បយុត្តភាគេបិ
បដិច្ចវារសទិសា ។

(៤២២) អព្យាកតោ អនារម្មណោ ធម្មោ អព្យាកតស្ស អនារម្មណស្ស ធម្មស្ស សហជាតប្បច្ចយេន បច្ចយោ ... អញ្ញមញ្ញប្បច្ចយេន បច្ចយោ និស្សយប្បច្ចយេន បច្ចយោ អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ អត្ថិប្បច្ចយេន បច្ចយោ អវិគតប្បច្ចយេន បច្ចយោ ។ សព្វត្ថ ឯកំ ។

កុសលត្តិកសារម្មណទុកំ និដ្ឋិតំ ។

## កុសលត្តិកចិត្តទុកំ

(៤២៣) កុសលោ ចិត្តោ ធម្មោ កុសលស្ស ចិត្តស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

(៤២៤) អារម្មណេ នវ អធិបតិយា សត្ត អវិគតេ សត្ត ។

(៤២៥) នហេតុយា នវ នអារម្មណេ នវ ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៤២៦) កុសលំ នោចិត្តំ ធម្មំ បដិច្ច កុសលោ នោចិត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៤៤២) អព្យាកតធម៌ មិនមានអារម្មណ៍ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានអារម្មណ៍ ដោយសហជាតប្បច្ច័យ ... ជាបច្ច័យ ដោយអញ្ញមញ្ញប្បច្ច័យ ជាបច្ច័យ ដោយនិស្សយប្បច្ច័យ ជាបច្ច័យ ដោយអាហារប្បច្ច័យ ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ ជាបច្ច័យ ដោយអវិគតប្បច្ច័យ ។ ក្នុងបច្ច័យទាំងអស់ សុទ្ធតែមានវារៈ ១ ។

ចប់ កុសលត្តិកសារម្មណទុកៈ ។

## កុសលត្តិកចិត្តទុកៈ

(៤៤៣) កុសលធម៌ ជាចិត្ត ជាបច្ច័យ នៃកុសលធម៌ ជាចិត្ត ដោយអារម្មណប្បច្ច័យ ។

(៤៤៤) ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

(៤៤៥) ក្នុងនហេតុប្បច្ច័យ មានវារៈ ៩ ក្នុងនអារម្មណប្បច្ច័យ មានវារៈ ៩ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

(៤៤៦) កុសលធម៌ មិនមែនជាចិត្ត អាស្រ័យនូវកុសលធម៌ មិនមែនជាចិត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

អកុសលំ នោចិត្តំ ធម្មំ បដិច្ច អកុសលោ នោចិត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ នោចិត្តំ ធម្មំ បដិច្ច អព្យាកតោ នោចិត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ នោចិត្តញ្ច អព្យាកតំ នោចិត្តញ្ច ធម្មំ បដិច្ច អព្យាកតោ នោចិត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ នោចិត្តញ្ច អព្យាកតំ នោចិត្តញ្ច ធម្មំ បដិច្ច អព្យាកតោ នោចិត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៦២៧) កុសលំ នោចិត្តំ ធម្មំ បដិច្ច កុសលោ នោចិត្តោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា ។

(៦២៨) ហេតុយា នវ អារម្មណេ តីណិ អធិបតិយា នវ អវិគតេ នវ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៦២៩) កុសលោ នោចិត្តោ ធម្មោ កុសលស្ស នោចិត្តស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៦៣០) ហេតុយា សត្ត អារម្មណេ នវ អធិបតិយា ទស អវិគតេ តេរស ។

កុសលត្តិកចិត្តទុកំ និដ្ឋិតំ ។

អកុសលធម៌ មិនមែនជាចិត្ត អាស្រ័យ នូវអកុសលធម៌ មិនមែនជាចិត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មាន៣ៈ ៣ ។ អព្យាកតធម៌ មិនមែនជាចិត្ត អាស្រ័យ នូវអព្យាកតធម៌ មិនមែនជាចិត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមែនជាចិត្ត អាស្រ័យ នូវកុសលធម៌ មិនមែនជាចិត្តផង នូវអព្យាកតធម៌ មិនមែនជាចិត្តផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមែនជាចិត្ត អាស្រ័យ នូវអកុសលធម៌ មិនមែនជាចិត្តផង នូវអព្យាកតធម៌ មិនមែនជាចិត្តផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤២៧) កុសលធម៌ មិនមែនជាចិត្ត អាស្រ័យ នូវកុសលធម៌ មិនមែនជាចិត្ត ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

(៤២៨) ក្នុងហេតុប្បច្ច័យ មាន៣ៈ ៩ ក្នុងអារម្មណប្បច្ច័យ មាន៣ៈ ៣ ក្នុងអធិបតិប្បច្ច័យ មាន៣ៈ ៩ ក្នុងអវិគតប្បច្ច័យ មាន៣ៈ ៩ ។

សហជាត៣ៈក្តី សម្បយុត្ត៣ៈក្តី ដូចគាទិនបដិច្ច៣ៈដែរ ។

(៤២៩) កុសលធម៌ មិនមែនជាចិត្ត ជាបច្ច័យ នៃកុសលធម៌ មិនមែនជាចិត្ត ដោយហេតុប្បច្ច័យ ។

(៤៣០) ក្នុងហេតុប្បច្ច័យ មាន៣ៈ ៧ ក្នុងអារម្មណប្បច្ច័យ មាន៣ៈ ៩ ក្នុងអធិបតិប្បច្ច័យ មាន៣ៈ ១០ ក្នុងអវិគតប្បច្ច័យ មាន៣ៈ ១៣ ។

ចប់ កុសលត្តិកបិត្តទុកៈ ។

# កុសលត្តិកចេតសិកទុកំ

(៤៣១) កុសលំ ចេតសិកំ ធម្មំ បដិច្ច កុសលោ ចេតសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ ចេតសិកំ ធម្មំ បដិច្ច អកុសលោ ចេតសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ ចេតសិកំ ធម្មំ បដិច្ច អព្យាកតោ ចេតសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៣២) ហេតុយា តីណិ អារម្មណេ តីណិ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៤៣៣) កុសលោ ចេតសិកោ ធម្មោ កុសលស្ស ចេតសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អកុសលោ ចេតសិកោ ធម្មោ អកុសលស្ស ចេតសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ ចេតសិកោ ធម្មោ អព្យាកតស្ស ចេតសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤៣៤) កុសលោ ចេតសិកោ ធម្មោ កុសលស្ស ចេតសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ ចេតសិកោ

# កុសលត្តិកចេតសិកទុកៈ

(៤៣១) កុសលធម៌ ជាចេតសិក អាស្រ័យ នូវកុសលធម៌ ជាចេតសិក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជាចេតសិក អាស្រ័យ នូវអកុសលធម៌ ជាចេតសិក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាចេតសិក អាស្រ័យ នូវអព្យាកតធម៌ ជាចេតសិក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៣២) ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៤៣៣) កុសលធម៌ ជាចេតសិក ជាបច្ច័យ នៃកុសលធម៌ ជាចេតសិក ដោយហេតុប្បច្ច័យ ។ អកុសលធម៌ ជាចេតសិក ជាបច្ច័យ នៃអកុសលធម៌ ជាចេតសិក ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាចេតសិក ជាបច្ច័យ នៃអព្យាកតធម៌ ជាចេតសិក ដោយហេតុប្បច្ច័យ ។

(៤៣៤) កុសលធម៌ ជាចេតសិក ជាបច្ច័យ នៃកុសលធម៌ ជាចេតសិក ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌

ធម្មោ អកុសលស្ស ចេតសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ ចេតសិកោ ធម្មោ អព្យាកតស្ស ចេតសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។

(៤៣៥) ហេតុយា តីណិ អារម្មណេ នវ អធិបតិយា សត្ត អវិគតេ តីណិ ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៤៣៦) កុសលំ អចេតសិកំ ធម្មំ បដិច្ច អព្យាកតោ អចេតសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៣៧) ហេតុយា បញ្ច អារម្មណេ ឯកំ អវិគតេ បញ្ច ។

(៤៣៨) នហេតុយា ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកចេតសិកទុកំ និដ្ឋិតំ ។

## កុសលត្តិកចិត្តសម្បយុត្តាទិអដ្ឋទុកំ

(៤៣៩) កុសលំ ចិត្តសម្បយុត្តំ ធម្មំ បដិច្ច ...

កុសលំ ចិត្តសំសដ្ឋំ ធម្មំ បដិច្ច ... កុសលំ

ជាចេតសិក ជាបច្ច័យ នៃអកុសលធម៌ ជាចេតសិក ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាចេតសិក ជាបច្ច័យ នៃអព្យាកតធម៌ ជាចេតសិក ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

(៤៣៥) ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៧ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

(៤៣៦) អព្យាកតធម៌ មិនមានចេតសិក អាស្រ័យ នូវកុសលធម៌ មិនមានចេតសិក ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៣៧) ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

(៤៣៨) ក្នុងនហេតុប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

ចប់ កុសលត្តិកចេតសិកទុកៈ ។

## កុសលត្តិកចិត្តសម្បយុត្តាទិអដ្ឋទុកៈ

(៤៣៩) អាស្រ័យ នូវកុសលធម៌ ប្រកបដោយចិត្ត ... អាស្រ័យ នូវកុសលធម៌ ប្រឡំដោយចិត្ត ... នូវកុសលធម៌

ចិត្តសមុដ្ឋានំ ... កុសលំ ចិត្តសហភុំ ... កុសលំ ចិត្តានុបរិវត្តិំ ... កុសលំ ចិត្តសំសដ្ឋសមុដ្ឋានំ ... កុសលំ ចិត្តសំសដ្ឋសមុដ្ឋានសហភុំ ... កុសលំ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិំ ធម្មំ បដិច្ច កុសលោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៤០) ហេតុយា តីណិ អារម្មណេ តីណិ អវិគតេ តីណិ ។

សហជាតវារេបិ សម្បយុត្តវារេបិ បញ្ហាវារេបិ
ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិទុកំ និដ្ឋិតំ ។

## កុសលត្តិកអជ្ឈត្តិកទុកំ

(៤៤១) អព្យាកតំ អជ្ឈត្តិកំ ធម្មំ បដិច្ច អព្យាកតោ អជ្ឈត្តិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៤២) ហេតុយា ឯកំ សហជាតេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

តាំងឡើងអំពីចិត្ត ... នូវកុសលធម៌ កើតជាមួយនឹងចិត្ត ... នូវកុសលធម៌ ប្រព្រឹត្តទៅតាមចិត្ត ... នូវកុសលធម៌ ច្រឡំ តាំងឡើងអំពីចិត្ត ... នូវកុសលធម៌ ច្រឡំ តាំងឡើង កើតជាមួយនឹងចិត្ត ... នូវកុសលធម៌ ច្រឡំ តាំងឡើងប្រព្រឹត្តទៅតាមចិត្ត អាស្រ័យ នូវកុសលធម៌ ច្រឡំ តាំងឡើងប្រព្រឹត្តទៅតាមចិត្ត ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៤០) ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បញ្ហាវារៈក្តី

បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនេះផងចុះ ។

ចប់ កុសលត្តិកចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិទុកៈ ។

## កុសលត្តិកអជ្ឈត្តិកទុកៈ

(៤៤១) អព្យាកតធម៌ ប្រព្រឹត្តទៅខាងក្នុង អាស្រ័យ នូវអព្យាកតធម៌ ប្រព្រឹត្តទៅខាងក្នុង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៤២) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងសហជាតប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

កុសលត្តិកអជ្ឈត្តិកទុកំ

(៤៤៣) កុសលោ អជ្ឈត្តិកោ ធម្មោ កុសលស្ស អជ្ឈត្តិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ កុសលោ អជ្ឈត្តិកោ ធម្មោ អកុសលស្ស អជ្ឈត្តិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ កុសលោ អជ្ឈត្តិកោ ធម្មោ អព្យាកតស្ស អជ្ឈត្តិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។ អកុសលោ អជ្ឈត្តិកោ ធម្មោ អកុសលស្ស អជ្ឈត្តិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ អជ្ឈត្តិកោ ធម្មោ អព្យាកតស្ស អជ្ឈត្តិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។

(៤៤៤) អារម្មណេ នវ បុរេជាតេ តីណិ អវិគតេ បញ្ច ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៤៤៥) កុសលំ ពាហិរំ ធម្មំ បដិច្ច កុសលោ ពាហិរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៤៦) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

[៤៤៣] កុសលធម៌ ប្រព្រឹត្តទៅខាងក្នុង ជាបច្ច័យ នៃកុសលធម៌ ប្រព្រឹត្តទៅខាងក្នុង ដោយអារម្មណប្បច្ច័យ កុសលធម៌ ប្រព្រឹត្តទៅខាងក្នុង ជាបច្ច័យ នៃអកុសលធម៌ ប្រព្រឹត្តទៅខាងក្នុង ដោយអារម្មណប្បច្ច័យ កុសលធម៌ ប្រព្រឹត្តទៅខាងក្នុង ជាបច្ច័យ នៃអព្យាកតធម៌ ប្រព្រឹត្តទៅខាងក្នុង ដោយអារម្មណប្បច្ច័យ ។ អកុសលធម៌ ប្រព្រឹត្តទៅខាងក្នុង ជាបច្ច័យ នៃអកុសលធម៌ ប្រព្រឹត្តទៅខាងក្នុង ដោយអារម្មណប្បច្ច័យ មាន៣វារៈ ។ អព្យាកតធម៌ ប្រព្រឹត្តទៅខាងក្នុង ជាបច្ច័យ នៃអព្យាកតធម៌ ប្រព្រឹត្តទៅខាងក្នុង ដោយអារម្មណប្បច្ច័យ មាន៣វារៈ ។

[៤៤៤] ក្នុងអារម្មណប្បច្ច័យ មាន៩វារៈ ក្នុងបុរេជាតប្បច្ច័យ មាន៣វារៈ ក្នុងអវិគតប្បច្ច័យ មាន៩វារៈ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

[៤៤៥] កុសលធម៌ ជាខាងក្រៅ អាស្រ័យ នូវកុសលធម៌ ជាខាងក្រៅ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៤៦] ក្នុងហេតុប្បច្ច័យ មាន៩វារៈ ក្នុងអារម្មណប្បច្ច័យ មាន៣វារៈ ក្នុងអវិគតប្បច្ច័យ មាន៩វារៈ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៤៤៧) កុសលោ ពាហិរោ ធម្មោ កុសលស្ស ពាហិរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤៤៨) ហេតុយា សត្ត អារម្មណេ នវ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្ពំ ។

កុសលត្តិកអជ្ឈត្តិកទុកំ និដ្ឋិតំ ។

## កុសលត្តិកឧបាទាទុកំ

(៤៤៩) អព្យាកតោ ឧបាទា ធម្មោ អព្យាកតស្ស ឧបាទា ធម្មស្ស អាហារប្បច្ចយេន បច្ចយោ ឥន្ទ្រិយប្បច្ចយេន បច្ចយោ អត្ថិប្បច្ចយេន បច្ចយោ អវិគតប្បច្ចយេន បច្ចយោ ។

(៤៥០) កុសលំ នោឧបាទា ធម្មំ បដិច្ច កុសលោ នោឧបាទា ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ នោឧបាទា ធម្មំ បដិច្ច អកុសលោ នោឧបាទា ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ នោឧបាទា ធម្មំ បដិច្ច អព្យាកតោ នោឧបាទា ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៤៤៧) កុសលធម៌ ជាខាងក្រៅ ជាបច្ច័យ នៃកុសលធម៌ ជាខាងក្រៅ ដោយហេតុប្បច្ច័យ ។

(៤៤៨) ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

ចប់ កុសលត្តិកអជ្ឈត្តិកទុកៈ ។

## កុសលត្តិកឧបាទាទុកៈ

(៤៤៩) អព្យាកតធម៌ ជាឧបាទា ជាបច្ច័យ នៃអព្យាកតធម៌ ជាឧបាទា ដោយអាហារប្បច្ច័យ ... ជាបច្ច័យ ដោយឥន្ទ្រិយប្បច្ច័យ ជាបច្ច័យ ដោយអត្ថិប្បច្ច័យ ជាបច្ច័យ ដោយអវិគតប្បច្ច័យ ។

(៤៥០) កុសលធម៌ មិនមែនជាឧបាទា អាស្រ័យ នូវកុសលធម៌ មិនមែនជាឧបាទា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ មិនមែនជាឧបាទា អាស្រ័យ នូវអកុសលធម៌ មិនមែនជាឧបាទា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមែនជាឧបាទា អាស្រ័យ នូវអព្យាកតធម៌ មិនមែនជាឧបាទា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៨១) ហេតុយា នវ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៤៨២) កុសលោ នោឧបាទា ធម្មោ កុសលស្ស នោឧបាទា ធម្មស្ស ហេតុបច្ចយេន បច្ចយោ តីណិ ។ អកុសលោ នោឧបាទា ធម្មោ អកុសលស្ស នោឧបាទា ធម្មស្ស ហេតុបច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ នោឧបាទា ធម្មោ អព្យាកតស្ស នោឧបាទា ធម្មស្ស ហេតុបច្ចយេន បច្ចយោ ។

(៤៨៣) កុសលោ នោឧបាទា ធម្មោ កុសលស្ស នោឧបាទា ធម្មស្ស អារម្មណបច្ចយេន បច្ចយោ តីណិ ។ អកុសលោ នោឧបាទា ធម្មោ អកុសលស្ស នោឧបាទា ធម្មស្ស អារម្មណបច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ នោឧបាទា ធម្មោ អព្យាកតស្ស នោឧបាទា ធម្មស្ស អារម្មណបច្ចយេន បច្ចយោ តីណិ ។

(៤៨៤) ហេតុយា សត្ត អារម្មណេ នវ អធិបតិយា នវ អវិគតេ ឯកាទស ។

[៤៩១] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៤៩២] កុសលធម៌ មិនមែនជាឧបាទា ជាបច្ច័យ នៃកុសលធម៌ មិនមែនជាឧបាទា ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ មិនមែនជាឧបាទា ជាបច្ច័យ នៃអកុសលធម៌ មិនមែនជាឧបាទា ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមែនជាឧបាទា ជាបច្ច័យ នៃអព្យាកតធម៌ មិនមែនជាឧបាទា ដោយហេតុប្បច្ច័យ ។

[៤៩៣] កុសលធម៌ មិនមែនជាឧបាទា ជាបច្ច័យ នៃកុសលធម៌ មិនមែនជាឧបាទា ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ មិនមែនជាឧបាទា ជាបច្ច័យ នៃអកុសលធម៌ មិនមែនជាឧបាទា ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមែនជាឧបាទា ជាបច្ច័យ នៃអព្យាកតធម៌ មិនមែនជាឧបាទា ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[៤៩៤] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអវិគតប្បច្ច័យ មានវារៈ ១១ ។

យថា កុសលត្តិកេ បញ្ហាវារស្មិំ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកឧបាទានទុកំ និដ្ឋិតំ ។

# កុសលត្តិកឧបាទិន្នទុកំ

(៤៥៥) អព្យាកតំ ឧបាទិន្នំ ធម្មំ បដិច្ច អព្យាកតោ ឧបាទិន្នោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

(៤៥៦) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៤៥៧) កុសលំ អនុបាទិន្នំ ធម្មំ បដិច្ច កុសលោ អនុបាទិន្នោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា តីណិ ។ អកុសលំ អនុបាទិន្នំ ធម្មំ បដិច្ច អកុសលោ អនុបាទិន្នោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា តីណិ ។ អព្យាកតំ អនុបាទិន្នំ ធម្មំ បដិច្ច អព្យាកតោ អនុបាទិន្នោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

(៤៥៨) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

ចប់ កុសលត្តិកឧបាទាទុកៈ ។

# កុសលត្តិកឧបាទិន្នទុកៈ

(៤៥៥) អព្យាកតធម៌ ជាឧបាទិន្ន អាស្រ័យ នូវអព្យាកតធម៌ ជាឧបាទិន្ន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៥៦) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

(៤៥៧) កុសលធម៌ ជាអនុបាទិន្ន អាស្រ័យ នូវកុសលធម៌ ជាអនុបាទិន្ន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអនុបាទិន្ន អាស្រ័យ នូវអកុសលធម៌ ជាអនុបាទិន្ន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអនុបាទិន្ន អាស្រ័យ នូវអព្យាកតធម៌ ជាអនុបាទិន្ន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៥៨) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

## កុសលត្តិកឧបាទិន្នទុកំ

(៦៥៩) កុសលោ អនុបាទិន្នោ ធម្មោ កុសលស្ស អនុបាទិន្នស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ អនុបាទិន្នោ ធម្មោ អកុសលស្ស អនុបាទិន្នស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ អនុបាទិន្នោ ធម្មោ អព្យាកតស្ស អនុបាទិន្នស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៦៦០) កុសលោ អនុបាទិន្នោ ធម្មោ កុសលស្ស អនុបាទិន្នស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ អនុបាទិន្នោ ធម្មោ អកុសលស្ស អនុបាទិន្នស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ អនុបាទិន្នោ ធម្មោ អព្យាកតស្ស អនុបាទិន្នស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ អព្យាកតោ អនុបាទិន្នោ ធម្មោ កុសលស្ស អនុបាទិន្នស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។

(៦៦១) ហេតុយា សត្ត អារម្មណេ នវ អធិបតិយា ទស អនន្តរេ ឆ សហជាតេ នវ និស្សយេ នវ ឧបនិស្សយេ នវ អវិគតេ ឯកាទស ។

កុសលត្តិកឧបាទិន្នទុកំ និដ្ឋិតំ ។

កុសលត្តិកឧបាទិន្នទុកៈ

[ ៤៥៩ ] កុសលធម៌ ជាអនុបាទិន្ន ជាបច្ច័យ នៃកុសលធម៌ ជាអនុបាទិន្ន ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអនុបាទិន្ន ជាបច្ច័យ នៃអកុសលធម៌ ជាអនុបាទិន្ន ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអនុបាទិន្ន ជាបច្ច័យ នៃអព្យាកតធម៌ ជាអនុបាទិន្ន ដោយហេតុប្បច្ច័យ ។

[ ៤៦០ ] កុសលធម៌ ជាអនុបាទិន្ន ជាបច្ច័យ នៃកុសលធម៌ ជាអនុបាទិន្ន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអនុបាទិន្ន ជាបច្ច័យ នៃអកុសលធម៌ ជាអនុបាទិន្ន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអនុបាទិន្ន ជាបច្ច័យ នៃអព្យាកតធម៌ ជាអនុបាទិន្ន ដោយអារម្មណប្បច្ច័យ អព្យាកតធម៌ ជាអនុបាទិន្ន ជាបច្ច័យ នៃកុសលធម៌ ជាអនុបាទិន្ន ដោយអារម្មណប្បច្ច័យ មានវារៈ ៣ ។

[ ៤៦១ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ១០ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៦ ក្នុងសហជាតប្បច្ច័យ មានវារៈ ៩ ក្នុងនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១១ ។

ចប់ កុសលត្តិកឧបាទិន្នទុកៈ ។

## កុសលត្តិកឧបាទានគោច្ឆកទុកំ

(៤៦២) អកុសលំ ឧបាទានំ ធម្មំ បដិច្ច អកុសលោ ឧបាទានោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៦៣) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

ឧបាទានគោច្ឆកំ វិត្ថារេតព្វំ ។

កុសលត្តិកឧបាទានគោច្ឆកទុកំ និដ្ឋិតំ ។

## កុសលត្តិកកិលេសទុកំ

(៤៦៤) អកុសលំ កិលេសំ ធម្មំ បដិច្ច អកុសលោ កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៦៥) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៤៦៦) កុសលំ នោកិលេសំ ធម្មំ បដិច្ច កុសលោ នោកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ នោកិលេសំ ធម្មំ បដិច្ច អកុសលោ នោកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ នោកិលេសំ ធម្មំ បដិច្ច អព្យាកតោ នោកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

# កុសលត្តិកឧបាទានគោច្ឆកទុកៈ

( ៤៦២ ) អកុសលធម៌ ជាឧបាទាន អាស្រ័យ នូវអកុសលធម៌ ជាឧបាទាន ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៤៦៣ ) ក្នុងហេតុប្បច្ច័យ មានវារៈ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១ ។

ឧបាទានគោច្ឆកៈ បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

ចប់ កុសលត្តិកឧបាទានគោច្ឆកទុកៈ ។

# កុសលត្តិកកិលេសទុកៈ

( ៤៦៤ ) អកុសលធម៌ ជាកិលេស អាស្រ័យ នូវអកុសលធម៌ ជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៤៦៥ ) ក្នុងហេតុប្បច្ច័យ មានវារៈ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ១ ។

( ៤៦៦ ) កុសលធម៌ មិនមែនជាកិលេស អាស្រ័យ នូវកុសលធម៌ មិនមែនជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ៣ ។ អកុសលធម៌ មិនមែនជាកិលេស អាស្រ័យ នូវអកុសលធម៌ មិនមែនជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ៣ ។ អព្យាកតធម៌ មិនមែនជាកិលេស អាស្រ័យ នូវអព្យាកតធម៌ មិនមែនជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៦៧) ហេតុយា ឆ អារម្មណេ តីណិ អធិ-
បតិយា ឆ អវិគតេ ឆ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៤៦៨) កុសលោ នោកិលេសោ ធម្មោ កុសលស្ស នោកិលេសស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ នោកិលេសោ ធម្មោ អព្យាកតស្ស នោកិលេសស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤៦៩) ហេតុយា ចត្តារិ អារម្មណេ ឆ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកកិលេសទុកំ និដ្ឋិតំ ។

## កុសលត្តិកសង្កិលេសិកទុកំ

(៤៧០) កុសលំ សង្កិលេសិកំ ធម្មំ បដិច្ច កុសលោ សង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ សង្កិលេសិកំ ធម្មំ បដិច្ច អកុសលោ សង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ

[៤៦៧] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។ សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៤៦៧] កុសលធម៌ មិនមែនជាកិលេស ជាបច្ច័យ នៃកុសលធម៌ មិនមែនជាកិលេស ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមែនជាកិលេស ជាបច្ច័យ នៃអព្យាកតធម៌ មិនមែនជាកិលេស ដោយហេតុប្បច្ច័យ ។

[៤៦៩] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា

បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

ចប់ កុសលត្តិកកិលេសទុកៈ ។

## កុសលត្តិកសង្កិលេសិកទុកៈ

[៤៧០] កុសលធម៌ គួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវកុសលធម៌ គួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ គួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវអកុសលធម៌ គួរដល់សេចក្តីសៅហ្មង ទើបកើតឡើង

ហេតុប្បច្ចយា តីណិ ។ អព្យាកតំ សង្កិលេសិកំ ធម្មំ បដិច្ច អព្យាកតោ សង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៨៧១) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតភាគេបិ សម្បយុត្តភាគេបិ វិត្ថារេតព្វា(១) ។

(៨៧២) កុសលោ សង្កិលេសិកោ ធម្មោ កុសលស្ស សង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ សង្កិលេសិកោ ធម្មោ អកុសលស្ស សង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ សង្កិលេសិកោ ធម្មោ អព្យាកតស្ស សង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៨៧៣) ហេតុយា សត្ត អារម្មណេ នវ អធិបតិយា នវ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៨៧៤) កុសលំ អសង្កិលេសិកំ ធម្មំ បដិច្ច កុសលោ អសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ

---

១ ម. សហជាតភាគេបិ សម្បយុត្តភាគេបិ វិត្ថារេតព្វាតិ ឥមេ បាឋា នត្ថិ ។

ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ គួរដល់សេចក្តីសៅ-ហ្មង អាស្រ័យ នូវអព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៧១) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

(៤៧២) កុសលធម៌ គួរដល់សេចក្តីសៅហ្មង ជាបច្ច័យ នៃកុសលធម៌ គួរដល់សេចក្តីសៅហ្មង ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ គួរដល់នូវសេចក្តីសៅហ្មង ជាបច្ច័យ នៃអកុសលធម៌ គួរដល់សេចក្តីសៅហ្មង ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ជាបច្ច័យ នៃអព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ដោយហេតុប្បច្ច័យ ។

(៤៧៣) ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

(៤៧៤) កុសលធម៌ មិនគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវកុសលធម៌ មិនគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង

ហេតុប្បច្ចយា ។ អព្យាកតំ អសង្កិលេសិកំ ធម្មំ បដិច្ច អព្យាកតោ អសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៧៥) ហេតុយា ទ្វេ អារម្មណេ ទ្វេ អវិគតេ ទ្វេ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៤៧៦) កុសលោ អសង្កិលេសិកោ ធម្មោ កុសលស្ស អសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ អសង្កិលេសិកោ ធម្មោ អព្យាកតស្ស អសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤៧៧) អព្យាកតោ អសង្កិលេសិកោ ធម្មោ អព្យាកតស្ស អសង្កិលេសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។ អព្យាកតោ អសង្កិលេសិកោ ធម្មោ កុសលស្ស អសង្កិលេសិកស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

(៤៧៨) ហេតុយា ទ្វេ អារម្មណេ ទ្វេ អធិបតិយា តីណិ អនន្តរេ ទ្វេ ឧបនិស្សយេ ចត្តារិ អវិគតេ ទ្វេ ។

ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវអព្យាកតធម៌ មិនគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៧៥] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៤៧៦] កុសលធម៌ មិនគួរដល់សេចក្តីសៅហ្មង ជាបច្ច័យ នៃកុសលធម៌ មិនគួរដល់សេចក្តីសៅហ្មង ដោយហេតុប្បច្ច័យ អព្យាកតធម៌ មិនគួរដល់សេចក្តីសៅហ្មង ជាបច្ច័យ នៃអព្យាកតធម៌ មិនគួរដល់សេចក្តីសៅហ្មង ដោយហេតុប្បច្ច័យ ។

[៤៧៧] អព្យាកតធម៌ មិនគួរដល់សេចក្តីសៅហ្មង ជាបច្ច័យ នៃអព្យាកតធម៌ មិនគួរដល់សេចក្តីសៅហ្មង ដោយអារម្មណប្បច្ច័យ ។ អព្យាកតធម៌ មិនគួរដល់សេចក្តីសៅហ្មង ជាបច្ច័យ នៃកុសលធម៌ មិនគួរដល់សេចក្តីសៅហ្មង ដោយអារម្មណប្បច្ច័យ ។

[៤៧៨] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

យថា កុសលត្តិកេ បញ្ហាវារស្មឹ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកសង្កិលេសិកទុកំ និដ្ឋិតំ ។

## កុសលត្តិកសង្កិលិដ្ឋទុកំ

(៤៧៩) អកុសលំ សង្កិលិដ្ឋំ ធម្មំ បដិច្ច អកុសលោ សង្កិលិដ្ឋោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៨០) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៤៨១) កុសលំ អសង្កិលិដ្ឋំ ធម្មំ បដិច្ច កុសលោ អសង្កិលិដ្ឋោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ អសង្កិលិដ្ឋំ ធម្មំ បដិច្ច អព្យាកតោ អសង្កិលិដ្ឋោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ អសង្កិលិដ្ឋំ ធម្មំ បដិច្ច កុសលោ អសង្កិលិដ្ឋោ ច អព្យាកតោ អសង្កិលិដ្ឋោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ អព្យាកតំ អសង្កិលិដ្ឋំ ធម្មំ បដិច្ច អព្យាកតោ អសង្កិលិដ្ឋោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ទ្វេ ។

(៤៨២) កុសលំ អសង្កិលិដ្ឋំ ធម្មំ បដិច្ច កុសលោ អសង្កិលិដ្ឋោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា ។

ឯបញ្ហាវារៈ គួរកុសលត្តិកៈ យ៉ាងណា

បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

ចប់ កុសលត្តិកសង្កិលេសិកទុកៈ ។

# កុសលត្តិកសង្កិលិដ្ឋទុកៈ

( ៤៧៩ ) អកុសលធម៌ ដែលសៅហ្មង អាស្រ័យ នូវអកុសលធម៌ ដែលសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៤៨០ ) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

( ៤៨១ ) កុសលធម៌ ដែលមិនសៅហ្មង អាស្រ័យ នូវកុសលធម៌ ដែលមិនសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ដែលមិនសៅហ្មង អាស្រ័យ នូវកុសលធម៌ ដែលមិនសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ ដែលមិនសៅហ្មងក្តី អព្យាកតធម៌ ដែលមិនសៅហ្មងក្តី អាស្រ័យ នូវកុសលធម៌ ដែលមិនសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលមិនសៅហ្មង អាស្រ័យ នូវអព្យាកតធម៌ ដែលមិនសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ២ ។

( ៤៨២ ) កុសលធម៌ ដែលមិនសៅហ្មង អាស្រ័យ នូវកុសលធម៌ ដែលមិនសៅហ្មង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

អព្យាកតំ អសង្កិលិដ្ឋំ ធម្មំ បដិច្ច អព្យាកតោ អសង្កិលិដ្ឋោ ធម្មោ ឧប្បជ្ជតិ អារម្មណប្បច្ចយា ។

(៤៨៣) ហេតុយា បញ្ច អារម្មណេ ទ្វេ អធិបតិយា បញ្ច អវិគតេ បញ្ច ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៤៨៤) កុសលោ អសង្កិលិដ្ឋោ ធម្មោ កុសលស្ស អសង្កិលិដ្ឋស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ អសង្កិលិដ្ឋោ ធម្មោ អព្យាកតស្ស អសង្កិលិដ្ឋស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤៨៥) កុសលោ អសង្កិលិដ្ឋោ ធម្មោ កុសលស្ស អសង្កិលិដ្ឋស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទ្វេ ។ អព្យាកតោ អសង្កិលិដ្ឋោ ធម្មោ អព្យាកតស្ស អសង្កិលិដ្ឋស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ទ្វេ ។

(៤៨៦) ហេតុយា ចត្តារិ អារម្មណេ ចត្តារិ អធិបតិយា បញ្ច អនន្តរេ ចត្តារិ ឧបនិស្សយេ ចត្តារិ អវិគតេ សត្ត ។

អព្យាកតធម៌ ដែលមិនសៅហ្មង អាស្រ័យ នូវអព្យាកតធម៌ ដែលមិនសៅហ្មង ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

[៤៨៣] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៤៨៤] កុសលធម៌ ដែលមិនសៅហ្មង ជាបច្ច័យ នៃកុសលធម៌ ដែលមិនសៅហ្មង ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ដែលមិនសៅហ្មង ជាបច្ច័យ នៃអព្យាកតធម៌ ដែលមិនសៅហ្មង ដោយហេតុប្បច្ច័យ ។

[៤៨៥] កុសលធម៌ ដែលមិនសៅហ្មង ជាបច្ច័យ នៃកុសលធម៌ ដែលមិនសៅហ្មង ដោយអារម្មណប្បច្ច័យ មានវារៈ ២ ។ អព្យាកតធម៌ ដែលមិនសៅហ្មង ជាបច្ច័យ នៃអព្យាកតធម៌ ដែលមិនសៅហ្មង ដោយអារម្មណប្បច្ច័យ មានវារៈ ២ ។

[៤៨៦] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៥ ក្នុងអនន្តរប្បច្ច័យ មានវារៈ ៤ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

យថា កុសលត្តិកេ បញ្ហាវារស្មឹ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកសង្កិលិដ្ឋទុកំ និដ្ឋិតំ ។

## កុសលត្តិកកិលេសសម្បយុត្តទុកំ

(៤៨៧) អកុសលំ កិលេសសម្បយុត្តំ ធម្មំ បដិច្ច អកុសលោ កិលេសសម្បយុត្តោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា សង្កិលិដ្ឋទុកសទិសំ ។

កុសលត្តិកកិលេសសម្បយុត្តទុកំ និដ្ឋិតំ ។

## កុសលត្តិកកិលេសសង្កិលេសិកទុកំ

(៤៨៨) អកុសលំ កិលេសញ្ចេវ សង្កិលេសិកញ្ច ធម្មំ បដិច្ច អកុសលោ កិលេសោ ចេវ សង្កិលេសិកោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៨៩) ហេតុយា ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៤៩០) កុសលំ សង្កិលេសិកញ្ចេវ នោ ច កិលេសំ ធម្មំ បដិច្ច កុសលោ សង្កិលេសិកោ ចេវ នោ ច កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

ឯបញ្ហាវារៈ គួរកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

ចប់ កុសលត្តិកសង្កិលិដ្ឋទុកៈ ។

# កុសលត្តិកកិលេសសម្បយុត្តទុកៈ

( ៤៨៧ ) អកុសលធម៌ ប្រកបដោយកិលេស អាស្រ័យ នូវអកុសលធម៌ ប្រកបដោយកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ប្រហែលគ្នានឹងសង្កិលិដ្ឋទុកៈដែរ ។

ចប់ កុសលត្តិកកិលេសសម្បយុត្តទុកៈ ។

# កុសលត្តិកកិលេសសង្កិលេសិកទុកៈ

( ៤៨៨ ) អកុសលធម៌ ជាកិលេស ទាំងគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវអកុសលធម៌ ជាកិលេស ទាំងគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៤៨៩ ) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

( ៤៩០ ) កុសលធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស អាស្រ័យ នូវកុសលធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

អកុសលំ សង្កិលេសិកញ្ចេវ នោចកិលេសំ ធម្មំ បដិច្ច អកុសលោ សង្កិលេសិកោចេវ នោចកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ សង្កិលេសិកញ្ចេវ នោចកិលេសំ ធម្មំ បដិច្ច អព្យាកតោ សង្កិលេសិកោចេវ នោចកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ សង្កិលេសិកញ្ចេវ នោចកិលេសញ្ច អព្យាកតំ សង្កិលេសិកញ្ចេវ នោចកិលេសញ្ច ធម្មំ បដិច្ច អព្យាកតោ សង្កិលេសិកោចេវ នោចកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ សង្កិលេសិកញ្ចេវ នោចកិលេសញ្ច អព្យាកតំ សង្កិលេសិកញ្ចេវ នោចកិលេសញ្ច ធម្មំ បដិច្ច អព្យាកតោ សង្កិលេសិកោចេវ នោចកិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៩១) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារោបិ សម្បយុត្តវារោបិ

បដិច្ចវារសទិសា ។

កុសលត្តិកកិលេសសង្កិលេសិកទុកៈ

អកុសលធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស អាស្រ័យ នូវអកុសលធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស អាស្រ័យ នូវអព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស អាស្រ័យ នូវកុសលធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេសផង នូវអព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេសផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស អាស្រ័យ នូវអកុសលធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេសផង នូវអព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេសផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៩១) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៤៩២) កុសលោ សង្កិលេសិកោ ចេវ នោ ច កិលេសោ ធម្មោ កុសលស្ស សង្កិលេសិកស្ស ចេវ-នោ ច កិលេសស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ សង្កិលេសិកោ ចេវ នោ ច កិលេសោ ធម្មោ អព្យាកតស្ស សង្កិលេសិកស្ស ចេវ-នោ ច កិលេសស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤៩៣) ហេតុយា ចត្តារិ អារម្មណេ ឆ អធិបតិយា ឆ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាភេទំ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកកិលេសសង្កិលេសិកទុកំ និដ្ឋិតំ ។

## កុសលត្តិកកិលេសសង្កិលិដ្ឋទុកំ

(៤៩៤) អកុសលំ កិលេសញ្ចេវ សង្កិលិដ្ឋញ្ច ធម្មំ បដិច្ច អកុសលោ កិលេសោ ចេវ សង្កិលិដ្ឋោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៩៥) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៤៩២) កុសលធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស ជាបច្ច័យ នៃកុសលធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស ជាបច្ច័យ នៃអព្យាកតធម៌ គួរដល់សេចក្តីសៅហ្មង ទាំងមិនមែនជាកិលេស ដោយហេតុប្បច្ច័យ ។

(៤៩៣) ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

ចប់ កុសលត្តិកកិលេសសង្កិលេសិកទុកៈ ។

## កុសលត្តិកកិលេសសង្កិលិដ្ឋទុកៈ

(៤៩៤) អកុសលធម៌ ជាកិលេស ទាំងសៅហ្មង អាស្រ័យនូវអកុសលធម៌ ជាកិលេស ទាំងសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៩៥) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

(៤៩៦) អកុសលំ សង្កិលិដ្ឋញ្ចេវ នោ ច កិលេសំ ធម្មំ បដិច្ច អកុសលោ សង្កិលិដ្ឋោ ចេវ នោ ច កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៩៧) ហេតុយា ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

កុសលត្តិកកិលេសសង្កិលិដ្ឋទុកំ និដ្ឋិតំ ។

# កុសលត្តិកកិលេសកិលេសសម្បយុត្តទុកំ

(៤៩៨) អកុសលំ កិលេសញ្ចេវ កិលេសសម្បយុត្តញ្ច ធម្មំ បដិច្ច អកុសលោ កិលេសោ ចេវ កិលេសសម្បយុត្តោ ច ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៩៩) ហេតុយា ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៥០០) អកុសលំ កិលេសសម្បយុត្តញ្ចេវ នោ ច កិលេសំ ធម្មំ បដិច្ច អកុសលោ កិលេសសម្បយុត្តោ ចេវ នោ ច កិលេសោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥០១) ហេតុយា ឯកំ អវិគតេ ឯកំ ។

(៤៩៦) អកុសលធម៌ ដែលសៅហ្មងទាំងមិនមែនជាកិលេស អាស្រ័យ នូវអកុសលធម៌ ដែលសៅហ្មងទាំងមិនមែនជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៩៧) ក្នុងហេតុប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សុទ្ធតែមានវារៈ១ ។

ចប់ កុសលត្តិកកិលេសសង្កិលិដ្ឋទុកៈ ។

# កុសលត្តិកកិលេសកិលេសសម្បយុត្តទុកៈ

(៤៩៨) អកុសលធម៌ ជាកិលេសទាំងប្រកបដោយកិលេស អាស្រ័យ នូវអកុសលធម៌ ជាកិលេសទាំងប្រកបដោយកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៩៩) ក្នុងហេតុប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី សុទ្ធតែមានវារៈ១ ។

(៥០០) អកុសលធម៌ ប្រកបដោយកិលេសទាំងមិនមែនជាកិលេស អាស្រ័យ នូវអកុសលធម៌ ប្រកបដោយកិលេសទាំងមិនមែនជាកិលេស ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៥០១) ក្នុងហេតុប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

កុសលត្តិកកិលេសកិលេសសម្បយុត្តទុកំ និដ្ឋិតំ ។

# កុសលត្តិកកិលេសវិប្បយុត្តសង្កិលេសិកទុកំ

(៨០២) កុសលំ កិលេសវិប្បយុត្តំ សង្កិលេសិកំ ធម្មំ បដិច្ច កុសលោ កិលេសវិប្បយុត្តោ សង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ កិលេសវិប្បយុត្តំ សង្កិលេសិកំ ធម្មំ បដិច្ច អព្យាកតោ កិលេសវិប្បយុត្តោ សង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ កិលេសវិប្បយុត្តំ សង្កិលេសិកំ ធម្មំ បដិច្ច កុសលោ កិលេសវិប្បយុត្តោ សង្កិលេសិកោ ច អព្យាកតោ កិលេសវិប្បយុត្តោ សង្កិលេសិកោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ អព្យាកតំ កិលេសវិប្បយុត្តំ សង្កិលេសិកំ ធម្មំ បដិច្ច អព្យាកតោ កិលេសវិប្បយុត្តោ សង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ កិលេសវិប្បយុត្តំ សង្កិលេសិកញ្ច

គន្ថបច្ច័យទាំងអស់ គន្ថសហជាតវារៈក្តី បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ៗ

ចប់ កុសលត្តិកកិលេសកិលេសសម្បយុត្តទុកៈ ។

# កុសលត្តិកកិលេសវិប្បយុត្តសង្កិលេសិកទុកៈ

(៩០២) កុសលធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវកុសលធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវកុសលធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មងក្តី អព្យាកតធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មងក្តី អាស្រ័យ នូវកុសលធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវអព្យាកតធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មង អាស្រ័យ នូវកុសលធម៌ ដែលប្រាសចាកសេចក្តីសៅហ្មងទាំងគួរដល់សេចក្តីសៅហ្មងផង

អព្យាកតំ កិលេសវិប្បយុត្តំ សង្កិលេសិកញ្ច ធម្មំ បដិច្ច អព្យាកតោ កិលេសវិប្បយុត្តោ សង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៨០៣) ហេតុយា បញ្ច អារម្មណេ ទ្វេ អវិគតេ បញ្ច ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៨០៤) កុសលោ កិលេសវិប្បយុត្តោ សង្កិលេសិកោ ធម្មោ កុសលស្ស កិលេសវិប្បយុត្តស្ស-សង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ កិលេសវិប្បយុត្តោ សង្កិលេសិកោ ធម្មោ អព្យាកតស្ស កិលេសវិប្បយុត្តស្ស-សង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៨០៥) ហេតុយា ចត្តារិ អារម្មណេ ចត្តារិ អធិបតិយា ចត្តារិ អវិគតេ សត្ត ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៨០៦) កុសលំ កិលេសវិប្បយុត្តំ អសង្កិលេសិកំ ធម្មំ បដិច្ច កុសលោ កិលេសវិប្បយុត្តោ អសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ

នូវអព្យាកតធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មងផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៥០៣] ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្ដី សម្បយុត្តវារៈក្ដី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៥០៤] កុសលធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង ជាបច្ច័យ នៃកុសលធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង ជាបច្ច័យ នៃអព្យាកតធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង ដោយហេតុប្បច្ច័យ ។

[៥០៥] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្ដារ យ៉ាងនោះផងចុះ ។

[៥០៦] កុសលធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងទាំងមិនគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវកុសលធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងទាំងមិនគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង

ហេតុប្បច្ចយា ។ អព្យាកតំ កិលេសវិប្បយុត្តំ អសង្កិលេសិកំ ធម្មំ បដិច្ច អព្យាកតោ កិលេសវិប្បយុត្តោ អសង្កិលេសិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥០៧) ហេតុយា ទ្វេ អវិគតេ ទ្វេ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៥០៨) កុសលោ កិលេសវិប្បយុត្តោ អសង្កិលេសិកោ ធម្មោ កុសលស្ស កិលេសវិប្បយុត្តស្ស អសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ កិលេសវិប្បយុត្តោ អសង្កិលេសិកោ ធម្មោ អព្យាកតស្ស កិលេសវិប្បយុត្តស្ស អសង្កិលេសិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៥០៩) ហេតុយា ទ្វេ អារម្មណេ ទ្វេ អធិបតិយា តីណិ អនន្តរេ ទ្វេ ឧបនិស្សយេ ចត្តារិ អវិគតេ ទ្វេ ។

ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងផង មិនគួរដល់សេចក្ដីសៅហ្មង អាស្រ័យ នូវអព្យាកតធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងផងមិនគួរដល់សេចក្ដីសៅហ្មង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៩០៧ ) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

( ៩០៨ ) កុសលធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងផងមិនគួរដល់សេចក្ដីសៅហ្មង ជាបច្ច័យ នៃកុសលធម៌ ដែលប្រាសចាក-សេចក្ដីសៅហ្មងផងមិនគួរដល់សេចក្ដីសៅហ្មង ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលប្រាសចាកសេចក្ដីសៅហ្មងផងមិនគួរដល់សេចក្ដីសៅហ្មង ជាបច្ច័យ នៃអព្យាកតធម៌ ដែលប្រាសចាកសេចក្ដីសៅ-ហ្មងផងមិនគួរដល់សេចក្ដីសៅហ្មង ដោយហេតុប្ប-ច្ច័យ ។

( ៩០៩ ) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

កុសលត្តិកទស្សនេនបហាតព្វទុកំ

យថា កុសលត្តិកេ បញ្ហាវារស្មិំ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកកិលេសវិប្បយុត្តសង្កិលេសិកទុកំ និដ្ឋិតំ ។

## កុសលត្តិកទស្សនេនបហាតព្វទុកំ

(៨១០) អកុសលំ ទស្សនេន បហាតព្វំ ធម្មំ បដិច្ច អកុសលោ ទស្សនេន បហាតព្វោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៨១១) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៨១២) កុសលំ នទស្សនេន បហាតព្វំ ធម្មំ បដិច្ច កុសលោ នទស្សនេន បហាតព្វោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ នទស្សនេនបហាតព្វំ ធម្មំ បដិច្ច អកុសលោ នទស្សនេន បហាតព្វោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ នទស្សនេន បហាតព្វំ ធម្មំ បដិច្ច អព្យាកតោ នទស្សនេន បហាតព្វោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ នទស្សនេន បហាតព្វញ្ច អព្យាកតំ នទស្សនេន បហាតព្វញ្ច ធម្មំ បដិច្ច អព្យាកតោ នទស្សនេន បហាតព្វោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

ឯបញ្ហាវារៈ គន់កុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

ចប់ កុសលត្តិកកិលេសវិប្បយុត្តសង្កិលេសិកទុកៈ ។

## កុសលត្តិកទស្សនេនបហាតព្វទុកៈ

[៥១០] អកុសលធម៌ ត្រូវលះដោយទស្សនៈ អាស្រ័យ នូវកុសលធម៌ ត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៥១១] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអារម្មណប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[៥១២] កុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ អាស្រ័យ នូវកុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ អាស្រ័យ នូវអកុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ អាស្រ័យ នូវអព្យាកតធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ អាស្រ័យ នូវកុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈផង នូវអព្យាកតធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

អកុសលំ ច នទស្សនេន បហាតព្វញ្ច អព្យាកតំ ច-នទស្សនេន បហាតព្វញ្ច ធម្មំ បដិច្ច អព្យាកតោ ន-ទស្សនេន បហាតព្វោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥១៣) ហេតុយា ទ្វេ អារម្មណេ តីណិ អវិ-គតេ ទ្វេ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៥១៤) កុសលោ នទស្សនេន បហាតព្វោ ធម្មោ កុសលស្ស នទស្សនេន បហាតព្វស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ ន-ទស្សនេន បហាតព្វោ ធម្មោ អកុសលស្ស នទស្ស-នេន បហាតព្វស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ នទស្សនេន បហាតព្វោ ធម្មោ អព្យាកតស្ស នទស្សនេន បហាតព្វស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៥១៥) ហេតុយា សត្ត អារម្មណេ ទ្វេ អធិ-បតិយា ទស អនន្តរេ សត្ត អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកនទស្សនេនបហាតព្វទុកំ និដ្ឋិតំ ។

អព្យាកតធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ អាស្រ័យ នូវអកុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈផង នូវអព្យាកតធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤១៣] ក្នុងហេតុប្បច្ច័យ មាន៩វារៈ ក្នុងអារម្មណប្បច្ច័យ មាន៣វារៈ ក្នុងអវិគតប្បច្ច័យ មាន៩វារៈ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៤១៤] កុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ជាបច្ច័យ នៃកុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ដោយហេតុប្បច្ច័យ មាន៣វារៈ ។ អកុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ជាបច្ច័យ នៃអកុសលធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ដោយហេតុប្បច្ច័យ មាន៣វារៈ ។ អព្យាកតធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ជាបច្ច័យ នៃអព្យាកតធម៌ ដែលមិនមែនត្រូវលះដោយទស្សនៈ ដោយហេតុប្បច្ច័យ ។

[៤១៥] ក្នុងហេតុប្បច្ច័យ មាន៧វារៈ ក្នុងអារម្មណប្បច្ច័យ មាន៩វារៈ ក្នុងអធិបតិប្បច្ច័យ មាន១០វារៈ ក្នុងអនន្តរប្បច្ច័យ មាន៧វារៈ ក្នុងអវិគតប្បច្ច័យ មាន១៣វារៈ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

ចប់ កុសលត្តិកទស្សនេនបហាតព្វទុកៈ ។

# កុសលត្តិកភាវនាយបហាតព្វទុកំ

(៥១៦) អកុសលំ ភាវនាយ បហាតព្វំ ធម្មំ បដិច្ច អកុសលោ ភាវនាយ បហាតព្វោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥១៧) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៥១៨) កុសលំ ន ភាវនាយ បហាតព្វំ ធម្មំ បដិច្ច កុសលោ ន ភាវនាយ បហាតព្វោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥១៩) ហេតុយា ឆ អារម្មណេ តីណិ ។

សហជាតវារម្បិ បញ្ហាវារម្បិ វិត្ថារេតព្វំ ។

កុសលត្តិកភាវនាយបហាតព្វទុកំ និដ្ឋិតំ ។

# កុសលត្តិកទស្សនេនបហាតព្វហេតុកទុកំ

(៥២០) អកុសលំ ទស្សនេន បហាតព្វហេតុកំ ធម្មំ បដិច្ច អកុសលោ ទស្សនេន បហាតព្វហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

# កុសលត្តិកភាវនាយបហាតព្វទុកៈ

[៥១៦] អកុសលធម៌ ដែលត្រូវលះដោយភាវនា អាស្រ័យនូវអកុសលធម៌ ដែលត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុ-បច្ច័យ ។

[៥១៧] ក្នុងហេតុបច្ច័យ មានវារៈ១ ក្នុងអារម្មណបច្ច័យ មានវារៈ១ ក្នុងអវិគតបច្ច័យ មានវារៈ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ១ ។

[៥១៨] កុសលធម៌ ដែលមិនមែនត្រូវលះដោយភាវនា អាស្រ័យនូវកុសលធម៌ ដែលមិនមែនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុបច្ច័យ ។

[៥១៩] ក្នុងហេតុបច្ច័យ មានវារៈ៩ ក្នុងអារម្មណបច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

ចប់ កុសលត្តិកភាវនាយបហាតព្វទុកៈ ។

# កុសលត្តិកទស្សនេនបហាតព្វហេតុកទុកៈ

[៥២០] អកុសលធម៌ មានហេតុដែលត្រូវលះដោយទស្សនៈ អាស្រ័យនូវអកុសលធម៌ មានហេតុដែលត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុបច្ច័យ ។

(៤២១) ហេតុយា ឯកំ អារម្មណេ ឯកំ អធិ-បតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៤២២) កុសលំ នទស្សនេន បហាតព្វហេតុកំ ធម្មំ បដិច្ច កុសលោ នទស្សនេន បហាតព្វហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

(៤២៣) ហេតុយា នវ ។

សហជាតវារេបិ បញ្ហាវារេបិ វិត្ថារេតព្វំ ។

កុសលត្តិកទស្សនេនបហាតព្វហេតុកទុកំ និដ្ឋិតំ ។

## កុសលត្តិកភាវនាយបហាតព្វហេតុកទុកំ

(៤២៤) អកុសលំ ភាវនាយ បហាតព្វហេតុកំ ធម្មំ បដិច្ច អកុសលោ ភាវនាយ បហាតព្វហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

(៤២៥) ហេតុយា ឯកំ អារម្មណេ ឯកំ អធិ-បតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៤២៦) កុសលំ នភាវនាយ បហាតព្វហេតុកំ ធម្មំ បដិច្ច កុសលោ នភាវនាយ បហាតព្វហេតុកោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

[៤៦១] កុសលត្តិកហេតុប្បច្ច័យ មានវារៈ ១ កុសលត្តិកអារម្មណប្បច្ច័យ មានវារៈ ១ កុសលត្តិកអវិគតប្បច្ច័យ មានវារៈ ១ ។

កុសលត្តិកបច្ច័យទាំងអស់ កុសលត្តិកសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[៤៦២] កុសលធម៌ មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ អាស្រ័យ នូវកុសលធម៌ មានហេតុដែលមិនមែនត្រូវលះដោយទស្សនៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៦៣] កុសលត្តិកហេតុប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

ចប់ កុសលត្តិកទស្សនេនបហាតព្វហេតុកទុកៈ ។

# កុសលត្តិកភាវនាយបហាតព្វហេតុកទុកៈ

[៤៦៤] អកុសលធម៌ មានហេតុដែលត្រូវលះដោយភាវនា អាស្រ័យ នូវអកុសលធម៌ មានហេតុដែលត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៦៥] កុសលត្តិកហេតុប្បច្ច័យ មានវារៈ ១ កុសលត្តិកអារម្មណប្បច្ច័យ មានវារៈ ១ កុសលត្តិកអវិគតប្បច្ច័យ មានវារៈ ១ ។

កុសលត្តិកបច្ច័យទាំងអស់ កុសលត្តិកសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[៤៦៦] កុសលធម៌ មានហេតុដែលមិនមែនត្រូវលះដោយភាវនា អាស្រ័យ នូវកុសលធម៌ មានហេតុដែលមិនមែនត្រូវលះដោយភាវនា ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤២៧) ហេតុយា ទ្វេ អារម្មណេ តីណិ អធិបតេ ទ្វេ ។

សហជាតវារម្បិ បញ្ហាវារម្បិ វិត្ថារេតព្វំ ។

កុសលត្តិកការវិនាយបរា តុហេតុកទុកំ និដ្ឋិតំ ។

## កុសលត្តិកសវិតក្កទុកំ

(៤២៨) កុសលំ សវិតក្កំ ធម្មំ បដិច្ច កុសលោ សវិតក្កោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ សវិតក្កំ ធម្មំ បដិច្ច អកុសលោ សវិតក្កោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ សវិតក្កំ ធម្មំ បដិច្ច អព្យាកតោ សវិតក្កោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤២៩) ហេតុយា តីណិ អារម្មណេ តីណិ អធិបតេ តីណិ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៤៣០) កុសលោ សវិតក្កោ ធម្មោ កុសលស្ស សវិតក្កស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អកុសលោ សវិតក្កោ ធម្មោ អកុសលស្ស

( ៥២៧ ) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារផងចុះ ។

ចប់ កុសលត្តិកភាវនាយបហាតព្វហេតុកទុកៈ ។

## កុសលត្តិកសវិតក្កទុកៈ

( ៥២៨ ) កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ អាស្រ័យ នូវកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ អាស្រ័យ នូវអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ អាស្រ័យ នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៥២៩ ) ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

( ៥៣០ ) កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ជាបច្ច័យ នៃកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ដោយហេតុប្បច្ច័យ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ជាបច្ច័យ នៃអកុសលធម៌

សវិតក្កស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ សវិតក្កោ ធម្មោ អព្យាកតស្ស សវិតក្កស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៨៣១) កុសលោ សវិតក្កោ ធម្មោ កុសលស្ស សវិតក្កស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ សវិតក្កោ ធម្មោ អកុសលស្ស សវិតក្កស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ សវិតក្កោ ធម្មោ អព្យាកតស្ស សវិតក្កស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ តីណិ ។

(៨៣២) ហេតុយា តីណិ អារម្មណេ នវ អធិបតិយា សត្ត អវិគតេ តីណិ ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៨៣៣) កុសលំ អវិតក្កំ ធម្មំ បដិច្ច កុសលោ អវិតក្កោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៨៣៤) ហេតុយា សត្ត អារម្មណេ ទ្វេ អវិគតេ សត្ត ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ដោយហេតុប្បច្ច័យ ។

( ៥៣១ ) កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ជាបច្ច័យ នៃកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ដោយអារម្មណប្បច្ច័យ មាន៣ៈ ៣ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ជាបច្ច័យ នៃអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ដោយអារម្មណប្បច្ច័យ មាន៣ៈ ៣ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងវិតក្កៈ ដោយអារម្មណប្បច្ច័យ មាន៣ៈ ៣ ។

( ៥៣២ ) ក្នុងហេតុប្បច្ច័យ មាន៣ៈ ៣ ក្នុងអារម្មណប្បច្ច័យ មាន៣ៈ៩ ក្នុងអធិបតិប្បច្ច័យ មាន៣ៈ ៧ ក្នុងអវិគតប្បច្ច័យ មាន៣ៈ ៣ ។

ឯបញ្ហា៣ៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

( ៥៣៣ ) កុសលធម៌ មិនមានវិតក្កៈ អាស្រ័យ នូវកុសលធម៌ មិនមានវិតក្កៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៥៣៤ ) ក្នុងហេតុប្បច្ច័យ មាន៣ៈ ៧ ក្នុងអារម្មណប្បច្ច័យ មាន៣ៈ ២ ក្នុងអវិគតប្បច្ច័យ មាន៣ៈ ៧ ។

សហជាត៣ៈក្តី សម្បយុត្ត៣ៈក្តី ដូចគ្នានឹងបដិច្ច៣ៈដែរ ។

(៥៣៥) កុសលោ អវិតក្កោ ធម្មោ កុសលស្ស អវិតក្កស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ អវិតក្កោ ធម្មោ អព្យាកតស្ស អវិតក្កស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៥៣៦) ហេតុយា ចត្តារិ អារម្មណេ ឆ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកសវិតក្កទុកំ និដ្ឋិតំ ។

## កុសលត្តិកសវិចារទុកំ

(៥៣៧) កុសលំ សវិចារំ ធម្មំ បដិច្ច កុសលោ សវិចារោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលសវិតក្កសទិសំ ។

កុសលត្តិកសវិចារទុកំ និដ្ឋិតំ ។

## កុសលត្តិកសប្បីតិកទុកំ

(៥៣៨) កុសលំ សប្បីតិកំ ធម្មំ បដិច្ច កុសលោ សប្បីតិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

[៩៣៥] កុសលធម៌ មិនមានវិតក្កៈ ជាបច្ច័យ នៃកុសលធម៌ មិនមានវិតក្កៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមានវិតក្កៈ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានវិតក្កៈ ដោយហេតុប្បច្ច័យ ។

[៩៣៦] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

ចប់ កុសលត្តិកសវិតក្កទុកៈ ។

# កុសលត្តិកសវិចារទុកៈ

[៩៣៧] កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិចារៈ អាស្រ័យនូវកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងវិចារៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ គឺ ដូចគ្នានឹងកុសលត្តិកសវិតក្កៈដែរ ។

ចប់ កុសលត្តិកសវិចារទុកៈ ។

# កុសលត្តិកសប្បីតិកទុកៈ

[៩៣៨] កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ អាស្រ័យនូវកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

អកុសលំ សប្បីតិកំ ធម្មំ បដិច្ច អកុសលោ សប្បីតិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ សប្បីតិកំ ធម្មំ បដិច្ច អព្យាកតោ សប្បីតិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៣៩) ហេតុយា តីណិ អារម្មណេ តីណិ អវិគតេ តីណិ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៤៤០) កុសលោ សប្បីតិកោ ធម្មោ កុសលស្ស សប្បីតិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អកុសលោ សប្បីតិកោ ធម្មោ អកុសលស្ស សប្បីតិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ សប្បីតិកោ ធម្មោ អព្យាកតស្ស សប្បីតិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៤៤១) ហេតុយា តីណិ អារម្មណេ នវ· អវិគតេ តីណិ ។

(៤៤២) កុសលំ អប្បីតិកំ ធម្មំ បដិច្ច កុសលោ អប្បីតិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ អាស្រ័យ នូវអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ អាស្រ័យ នូវអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៣៩] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៤៤០] កុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ជាបច្ច័យ នៃកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ដោយហេតុប្បច្ច័យ ។ អកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ជាបច្ច័យ នៃអកុសលធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ជាបច្ច័យ នៃអព្យាកតធម៌ ប្រព្រឹត្តទៅជាមួយនឹងបីតិ ដោយហេតុប្បច្ច័យ ។

[៤៤១] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

[៤៤២] កុសលធម៌ មិនមានបីតិ អាស្រ័យ នូវកុសលធម៌ មិនមានបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

អកុសលំ សប្បីតិកំ ធម្មំ បដិច្ច អកុសលោ សប្បីតិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ សប្បីតិកំ ធម្មំ បដិច្ច អព្យាកតោ សប្បីតិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ សប្បីតិកញ្ច អព្យាកតំ សប្បីតិកញ្ច ធម្មំ បដិច្ច អព្យាកតោ សប្បីតិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ សប្បីតិកញ្ច អព្យាកតំ សប្បីតិកញ្ច ធម្មំ បដិច្ច អព្យាកតោ សប្បីតិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៨៤៣) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៨៤៤) កុសលោ សប្បីតិកោ ធម្មោ កុសលស្ស សប្បីតិកស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៨៤៥) ហេតុយា សត្ត អារម្មណេ នវ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកសប្បីតិកទុកំ និដ្ឋិតំ ។

អកុសលធម៌ មិនមានបីតិ អាស្រ័យ នូវអកុសលធម៌ មិនមានបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមានបីតិ អាស្រ័យ នូវអព្យាកតធម៌ មិនមានបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានបីតិ អាស្រ័យ នូវកុសលធម៌ មិនមានបីតិផង នូវអព្យាកតធម៌ មិនមានបីតិផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានបីតិ អាស្រ័យ នូវអកុសល-ធម៌ មិនមានបីតិផង នូវអព្យាកតធម៌ មិនមានបីតិផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៥៤៣) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៥៤៤) កុសលធម៌ មិនមានបីតិ ជាបច្ច័យ នៃកុសលធម៌ មិនមានបីតិ ដោយហេតុប្បច្ច័យ ។

(៥៤៥) ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

ចប់ កុសលត្តិកសប្បីតិកទុកៈ ។

## កុសលត្តិកប្បីតិសហគតាទិត្តិទុកំ

[៤៤៦] កុសលំ បីតិសហគតំ ធម្មំ បដិច្ច កុសលោ បីតិសហគតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ នបីតិសហគតំ ធម្មំ បដិច្ច ... ។ កុសលំ សុខសហគតំ ធម្មំ បដិច្ច ... កុសលំ នសុខសហគតំ ធម្មំ បដិច្ច ... ។ កុសលំ ឧបេក្ខាសហគតំ ធម្មំ បដិច្ច ... កុសលំ នឧបេក្ខាសហគតំ ធម្មំ បដិច្ច .. ។

កុសលត្តិកប្បីតិសហគតាទិត្តិទុកំ និដ្ឋិតំ ។

## កុសលត្តិកកាមាវចរទុកំ

[៤៤៧] កុសលំ កាមាវចរំ ធម្មំ បដិច្ច កុសលោ កាមាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ កាមាវចរំ ធម្មំ បដិច្ច អព្យាកតោ កាមាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា កុសលំ កាមាវចរំ ធម្មំ បដិច្ច កុសលោ កាមាវចរោ ច អព្យាកតោ កាមាវចរោ ច ធម្មា ឧប្បជ្ជន្តិ ហេតុប្បច្ចយា ។ អកុសលំ កាមាវចរំ ធម្មំ បដិច្ច អកុសលោ កាមាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ កាមាវចរំ ធម្មំ បដិច្ច អព្យាកតោ កាមាវចរោ ធម្មោ ឧប្បជ្ជតិ

# កុសលត្តិកបីតិសហគតាទិត្តិទុកៈ

[៥៤៦] កុសលធម៌ ប្រកបដោយបីតិ អាស្រ័យ នូវកុសលធម៌ ប្រកបដោយបីតិ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អាស្រ័យ នូវកុសលធម៌ មិនមែនប្រកបដោយបីតិ ... ។ អាស្រ័យ នូវកុសលធម៌ ប្រកបដោយសុខ ... អាស្រ័យ នូវកុសលធម៌ មិនមែនប្រកបដោយសុខ ... ។ អាស្រ័យ នូវកុសលធម៌ ប្រកបដោយឧបេក្ខា ... អាស្រ័យ នូវកុសលធម៌ មិនមែនប្រកបដោយឧបេក្ខា ... ។

ចប់ កុសលត្តិកបីតិសហគតាទិត្តិទុកៈ ។

# កុសលត្តិកកាមាវចរទុកៈ

[៥៤៧] កុសលធម៌ ជាកាមាវចរ អាស្រ័យ នូវកុសលធម៌ ជាកាមាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ ជាកាមាវចរ អាស្រ័យ នូវកុសលធម៌ ជាកាមាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ កុសលធម៌ ជាកាមាវចរក្តី អព្យាកតធម៌ ជាកាមាវចរក្តី អាស្រ័យ នូវកុសលធម៌ ជាកាមាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ កុសលធម៌ ជាកាមាវចរ អាស្រ័យ នូវអកុសលធម៌ ជាកាមាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មាននព្វៈ ៣ ។ អព្យាកតធម៌ ជាកាមាវចរ អាស្រ័យ នូវអព្យាកតធម៌ ជាកាមាវចរ ទើបកើតឡើង

ហេតុប្បច្ចយា ។ កុសលំ កាមាវចរញ្ច អព្យាកតំ កាមាវចរញ្ច ធម្មំ បដិច្ច អព្យាកតោ កាមាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ កាមាវចរញ្ច អព្យាកតំ កាមាវចរញ្ច ធម្មំ បដិច្ច អព្យាកតោ កាមាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៤៨) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារេបិ សម្បយុត្តវារេបិ
បដិច្ចវារសទិសា ។

(៥៤៩) កុសលោ កាមាវចរោ ធម្មោ កុសលស្ស កាមាវចរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ កាមាវចរោ ធម្មោ អកុសលស្ស កាមាវចរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ កាមាវចរោ ធម្មោ អព្យាកតស្ស កាមាវចរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៥៥០) ហេតុយា សត្ត អារម្មណេ នវ អធិបតិយា នវ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារស្ស ឯវំ វិត្ថារេតព្វំ ។

ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាកាមាវចរ អាស្រ័យ នូវកុសល-ធម៌ ជាកាមាវចរផង នូវអព្យាកតធម៌ ជាកាមាវចរផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាកាមាវចរ អាស្រ័យ នូវអកុ-សលធម៌ ជាកាមាវចរផង នូវអព្យាកតធម៌ ជាកាមាវចរផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៤៨] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៤៤៩] កុសលធម៌ ជាកាមាវចរ ជាបច្ច័យ នៃកុសលធម៌ ជាកាមាវចរ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាកាមាវចរ ជាបច្ច័យ នៃអកុសលធម៌ ជាកាមាវចរ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាកាមាវចរ ជាបច្ច័យ នៃអព្យាកតធម៌ ជាកាមាវចរ ដោយហេតុប្បច្ច័យ ។

[៤៥០] ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

បញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

(៥៥១) កុសលំ នកាមាវចរំ ធម្មំ បដិច្ច កុសលោ នកាមាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ នកាមាវចរំ ធម្មំ បដិច្ច អព្យាកតោ នកាមាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៥២) ហេតុយា ទ្វេ អារម្មណេ ទ្វេ អវិគតេ ទ្វេ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៥៥៣) កុសលោ នកាមាវចរោ ធម្មោ កុសលស្ស នកាមាវចរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ នកាមាវចរោ ធម្មោ អព្យាកតស្ស នកាមាវចរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៥៥៤) កុសលោ នកាមាវចរោ ធម្មោ កុសលស្ស នកាមាវចរស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ កុសលោ នកាមាវចរោ ធម្មោ អព្យាកតស្ស នកាមាវចរស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។ អព្យាកតោ នកាមាវចរោ ធម្មោ

(៤៤១) កុសលធម៌ មិនមែនជាកាមាវចរ អាស្រ័យនូវកុសលធម៌ មិនមែនជាកាមាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមែនជាកាមាវចរ អាស្រ័យនូវអព្យាកតធម៌ មិនមែនជាកាមាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៤៤២) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៤៤៣) កុសលធម៌ មិនមែនជាកាមាវចរ ជាបច្ច័យ នៃកុសលធម៌ មិនមែនជាកាមាវចរ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមែនជាកាមាវចរ ជាបច្ច័យ នៃអព្យាកតធម៌ មិនមែនជាកាមាវចរ ដោយហេតុប្បច្ច័យ ។

(៤៤៤) កុសលធម៌ មិនមែនជាកាមាវចរ ជាបច្ច័យ នៃកុសលធម៌ មិនមែនជាកាមាវចរ ដោយអារម្មណប្បច្ច័យ កុសលធម៌ មិនមែនជាកាមាវចរ ជាបច្ច័យ នៃអព្យាកតធម៌ មិនមែនជាកាមាវចរ ដោយអារម្មណប្បច្ច័យ ។ អព្យាកតធម៌ មិនមែនជាកាមាវចរ

អព្យាកតស្ស នកាមាវចរស្ស ធម្មស្ស អារម្មណប្ប-
ច្ចយេន បច្ចយោ អព្យាកតោ នកាមាវចរោ ធម្មោ
កុសលស្ស នកាមាវចរស្ស ធម្មស្ស អារម្មណប្បច្ច-
យេន បច្ចយោ ។

(៥៥៥) ហេតុយា ទ្វេ អារម្មណេ ចត្តារិ អធិ-
បតិយា តីណិ អវិគតេ ទ្វេ ។

យថា កុសលត្តិកេ បញ្ហាវារស្មិំ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកកាមាវចរទុកំ និដ្ឋិតំ ។

# កុសលត្តិករូបាវចរទុកំ

(៥៥៦) កុសលំ រូបាវចរំ ធម្មំ បដិច្ច កុសលោ
រូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យា-
កតំ រូបាវចរំ ធម្មំ បដិច្ច អព្យាកតោ រូបាវចរោ
ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៥៧) ហេតុយា ទ្វេ អវិគតេ ទ្វេ ។

សហជាតវារេបិ បញ្ហាវារេបិ ឯវំ វិត្ថារេតព្វា ។

(៥៥៨) កុសលំ នរូបាវចរំ ធម្មំ បដិច្ច កុសលោ
នរូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

ជាបច្ច័យ នៃអព្យាកតធម៌ មិនមែនជាកាមាវចរ ដោយអារម្មណប្បច្ច័យ អព្យាកតធម៌ មិនមែនជាកាមាវចរ ជាបច្ច័យ នៃកុសលធម៌ មិនមែនជាកាមាវចរ ដោយអារម្មណប្បច្ច័យ ។

(៥៥៥) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។
ចប់ កុសលត្តិកកាមាវចរទុកៈ ។

## កុសលត្តិករូបាវចរទុកៈ

(៥៥៦) កុសលធម៌ ជារូបាវចរ អាស្រ័យ នូវកុសលធម៌ ជារូបាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជារូបាវចរ អាស្រ័យ នូវអព្យាកតធម៌ ជារូបាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៥៥៧) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារយ៉ាងនេះ ។

(៥៥៨) កុសលធម៌ មិនមែនជារូបាវចរ អាស្រ័យ នូវកុសលធម៌ មិនមែនជារូបាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

អកុសលំ នរូបាវចរំ ធម្មំ បដិច្ច អកុសលោ នរូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ នរូបាវចរំ ធម្មំ បដិច្ច អព្យាកតោ នរូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ នរូបាវចរញ្ច អព្យាកតំ នរូបាវចរញ្ច ធម្មំ បដិច្ច អព្យាកតោ នរូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ នរូបាវចរញ្ច អព្យាកតំ នរូបាវចរញ្ច ធម្មំ បដិច្ច អព្យាកតោ នរូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៥៩) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៥៦០) កុសលោ នរូបាវចរោ ធម្មោ កុសលស្ស នរូបាវចរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ នរូបាវចរោ ធម្មោ អកុសលស្ស នរូបាវចរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ នរូបាវចរោ ធម្មោ អព្យាកតស្ស នរូបាវចរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

អកុសលធម៌ មិនមែនជារូបាវចរ អាស្រ័យ នូវអកុសលធម៌ មិនមែនជារូបាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមែនជារូបាវចរ អាស្រ័យ នូវអព្យាកតធម៌ មិនមែនជារូបាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមែនជារូបាវចរ អាស្រ័យ នូវកុសលធម៌ មិនមែនជារូបាវចរផង នូវអព្យាកតធម៌ មិនមែនជារូបាវចរផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ អព្យាកតធម៌ មិនមែនជារូបាវចរ អាស្រ័យ នូវអកុសលធម៌ មិនមែនជារូបាវចរផង នូវអព្យាកតធម៌ មិនមែនជារូបាវចរផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៥៥៩] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

[៥៦០] កុសលធម៌ មិនមែនជារូបាវចរ ជាបច្ច័យ នៃកុសលធម៌ មិនមែនជារូបាវចរ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ មិនមែនជារូបាវចរ ជាបច្ច័យ នៃអកុសលធម៌ មិនមែនជារូបាវចរ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមែនជារូបាវចរ ជាបច្ច័យ នៃអព្យាកតធម៌ មិនមែនជារូបាវចរ ដោយហេតុប្បច្ច័យ ។

(៥៦១) ហេតុយា សត្ត អារម្មណេ ឯវំ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិករូបាវចរទុកំ និដ្ឋិតំ ។

## កុសលត្តិកអរូបាវចរទុកំ

(៥៦២) កុសលំ អរូបាវចរំ ធម្មំ បដិច្ច កុសលោ អរូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ អរូបាវចរំ ធម្មំ បដិច្ច អព្យាកតោ អរូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៦៣) កុសលំ នអរូបាវចរំ ធម្មំ បដិច្ច កុសលោ នអរូបាវចរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

រូបាវចរទុកសទិសំ ។

កុសលត្តិកអរូបាវចរទុកំ និដ្ឋិតំ ។

## កុសលត្តិកបរិយាបន្នទុកំ

(៥៦៤) កុសលំ បរិយាបន្នំ ធម្មំ បដិច្ច កុសលោ បរិយាបន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ បរិយាបន្នំ ធម្មំ បដិច្ច អកុសលោ បរិយាបន្នោ ធម្មោ ឧប្បជ្ជតិ

(៥៦១) ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្ដារ យ៉ាងនោះផងចុះ ។

ចប់ កុសលត្តិករូបាវចរទុកៈ ។

# កុសលត្តិកអរូបាវចរទុកៈ

(៥៦២) កុសលធម៌ ជាអរូបាវចរ អាស្រ័យ នូវកុសលធម៌ ជាអរូបាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអរូបាវចរ អាស្រ័យ នូវអព្យាកតធម៌ ជាអរូបាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៥៦៣) កុសលធម៌ មិនមែនជាអរូបាវចរ អាស្រ័យ នូវកុសលធម៌ មិនមែនជាអរូបាវចរ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(កុសលត្តិកអរូបាវចរទុកៈ) ដូចគ្នានឹងរូបាវចរទុកៈដែរ ។

ចប់ កុសលត្តិកអរូបាវចរទុកៈ ។

# កុសលត្តិកបរិយាបន្នទុកៈ

(៥៦៤) កុសលធម៌ ជាបរិយាបន្នៈ (ធម៌ដែលរាប់បញ្ចូលក្នុងតេភូមិកវដ្ដ) អាស្រ័យ នូវកុសលធម៌ ជាបរិយាបន្នៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាបរិយាបន្នៈ អាស្រ័យ នូវអកុសលធម៌ ជាបរិយាបន្នៈ ទើបកើតឡើង

ហេតុប្បច្ចយា តីណិ ។ អព្យាកតំ បរិយាបន្នំ ធម្មំ បដិច្ច អព្យាកតោ បរិយាបន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ កុសលំ បរិយាបន្នញ្ច អព្យាកតំ បរិយាបន្នញ្ច ធម្មំ បដិច្ច អព្យាកតោ បរិយាបន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ បរិយាបន្នញ្ច អព្យាកតំ បរិយាបន្នញ្ច ធម្មំ បដិច្ច អព្យាកតោ បរិយាបន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៦៥) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារោបិ សម្បយុត្តវារោបិ
បដិច្ចវារសទិសា ។

(៥៦៦) កុសលោ បរិយាបន្នោ ធម្មោ កុសលស្ស បរិយាបន្នស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អកុសលោ បរិយាបន្នោ ធម្មោ អកុសលស្ស បរិយាបន្នស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ បរិយាបន្នោ ធម្មោ អព្យាកតស្ស បរិយាបន្នស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាបរិយាបន្នៈ អាស្រ័យ នូវអព្យាកតធម៌ ជាបរិយាបន្នៈ ទើបកើតឡើង ព្រោះហេ-តុប្បច្ច័យ ។ អព្យាកតធម៌ ជាបរិយាបន្នៈ អាស្រ័យ នូវកុសលធម៌ ជាបរិយាបន្នៈផង នូវអព្យាកតធម៌ ជាបរិយាបន្នៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាបរិយាបន្នៈ អាស្រ័យ នូវអកុសលធម៌ ជាបរិយាបន្នៈផង នូវអព្យាកតធម៌ ជាបរិយាបន្នៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៥៦៥ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៤ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៥៦៦ ] កុសលធម៌ ជាបរិយាបន្នៈ ជាបច្ច័យ នៃកុសលធម៌ ជាបរិយាបន្នៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាបរិយាបន្នៈ ជាបច្ច័យ នៃអកុសលធម៌ ជាបរិយាបន្នៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាបរិយាបន្នៈ ជាបច្ច័យ នៃអព្យាកតធម៌ ជាបរិយាបន្នៈ ដោយហេតុប្បច្ច័យ ។

## កុសលត្តិកបរិយាបន្នទុកំ

(៤៦៧) ហេតុយា សត្ត អារម្មណេ នវ អធិបតិយា នវ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(៤៦៨) កុសលំ អបរិយាបន្នំ ធម្មំ បដិច្ច កុសលោ អបរិយាបន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ អបរិយាបន្នំ ធម្មំ បដិច្ច អព្យាកតោ អបរិយាបន្នោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៤៦៩) ហេតុយា ទ្វេ អារម្មណេ ទ្វេ អវិគតេ ទ្វេ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៤៧០) កុសលោ អបរិយាបន្នោ ធម្មោ កុសលស្ស អបរិយាបន្នស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ អព្យាកតោ អបរិយាបន្នោ ធម្មោ អព្យាកតស្ស អបរិយាបន្នស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

( ៩៦៧ ) ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

( ៩៦៨ ) កុសលធម៌ ជាអបរិយាបន្នៈ ( ធម៌ ដែលមិនបានរាប់បញ្ចូលក្នុងតេភូមិកវដ្ដ ) អាស្រ័យ នូវកុសលធម៌ ជាអបរិយាបន្នៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ ជាអបរិយាបន្នៈ អាស្រ័យ នូវអព្យាកតធម៌ ជាអបរិយាបន្នៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៩៦៩ ) ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្ដី សម្បយុត្តវារៈក្ដី ប្រហែលគ្នានឹងបដិច្ចវារៈដែរ ។

( ៩៧០ ) កុសលធម៌ ជាអបរិយាបន្នៈ ជាបច្ច័យ នៃកុសលធម៌ ជាអបរិយាបន្នៈ ដោយហេតុប្បច្ច័យ អព្យាកតធម៌ ជាអបរិយាបន្នៈ ជាបច្ច័យ នៃអព្យាកតធម៌ ជាអបរិយាបន្នៈ ដោយហេតុប្បច្ច័យ ។

(៥៧១) អព្យាកតោ អបរិយាបន្នោ ធម្មោ អព្យាកតស្ស អបរិយាបន្នស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ ។ អព្យាកតោ អបរិយាបន្នោ ធម្មោ កុសលស្ស អបរិយាបន្នស្ស ធម្មស្ស អារម្មណបច្ចយេន បច្ចយោ ។

(៥៧២) ហេតុយា ទ្វេ អារម្មណេ ទ្វេ អធិបតិយា តីណិ អនន្តរេ ទ្វេ ឧបនិស្សយេ ចត្តារិ អវិគតេ ទ្វេ ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកបរិយាបន្នទុកំ និដ្ឋិតំ ។

## កុសលត្តិកនិយ្យានិកទុកំ

(៥៧៣) កុសលំ និយ្យានិកំ ធម្មំ បដិច្ច កុសលោ និយ្យានិកោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

(៥៧៤) ហេតុយា ឯកំ អារម្មណេ ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

[៤៧១] អព្យាកតធម៌ ជាអបរិយាបន្នៈ ជាបច្ច័យ នៃអព្យាកតធម៌ ជាអបរិយាបន្នៈ ដោយអារម្មណប្បច្ច័យ ។ អព្យាកតធម៌ ជាអបរិយាបន្នៈ ជាបច្ច័យ នៃកុសលធម៌ ជាអបរិយាបន្នៈ ដោយអារម្មណប្បច្ច័យ ។

[៤៧២] ក្នុងហេតុប្បច្ច័យ មាន៦វារៈ ២ ក្នុងអារម្មណប្បច្ច័យ មាន៦វារៈ ២ ក្នុងអធិបតិប្បច្ច័យ មាន៦វារៈ ៣ ក្នុងអនន្តរប្បច្ច័យ មាន៦វារៈ ២ ក្នុងឧបនិស្សយប្បច្ច័យ មាន៦វារៈ ៤ ក្នុងអវិគតប្បច្ច័យ មាន៦វារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះផងចុះ ។

ចប់ កុសលត្តិកបរិយាបន្នទុកៈ ។

# កុសលត្តិកនិយ្យានិកទុកៈ

[៤៧៣] កុសលធម៌ ជានិយ្យានិកៈ (ធម៌ដែលលះបង់សង្សារវដ្តទាំងអស់ ដោយឥតមានសេសសល់) អាស្រ័យ នូវកុសលធម៌ ជានិយ្យានិកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៧៤] ក្នុងហេតុប្បច្ច័យ មាន៦វារៈ ១ ក្នុងអារម្មណប្បច្ច័យ មាន៦វារៈ ១ ក្នុងអវិគតប្បច្ច័យ មាន៦វារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

(៨៧៥) កុសលំ អនិយ្យានិកំ ធម្មំ បដិច្ច កុសលោ អនិយ្យានិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ អនិយ្យានិកំ ធម្មំ បដិច្ច អកុសលោ អនិយ្យានិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ អនិយ្យានិកំ ធម្មំ បដិច្ច អព្យាកតោ អនិយ្យានិកោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៨៧៦) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារម្បិ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកនិយ្យានិកទុកំ និដ្ឋិតំ ។

## កុសលត្តិកនិយតទុកំ

(៨៧៧) កុសលំ និយតំ ធម្មំ បដិច្ច កុសលោ និយតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អកុសលំ និយតំ ធម្មំ បដិច្ច អកុសលោ និយតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៨៧៨) ហេតុយា ទ្វេ អារម្មណេ ទ្វេ អវិគតេ ទ្វេ ។

សហជាតវារម្បិ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកនិយតទុកៈ

[៤៧៥] កុសលធម៌ ជាអនិយ្យានិកៈ អាស្រ័យ នូវកុសលធម៌ ជាអនិយ្យានិកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ជាអនិយ្យានិកៈ អាស្រ័យ នូវអកុសលធម៌ ជាអនិយ្យានិកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ជាអនិយ្យានិកៈ អាស្រ័យ នូវអព្យាកតធម៌ ជាអនិយ្យានិកៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៧៦] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនេះចុះ ។

ចប់ កុសលត្តិកនិយ្យានិកទុកៈ ។

# កុសលត្តិកនិយតទុកៈ

[៤៧៧] កុសលធម៌ ជានិយតៈ (ធម៌ទៀង) អាស្រ័យ នូវកុសលធម៌ ជានិយតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អកុសលធម៌ ជានិយតៈ អាស្រ័យ នូវអកុសលធម៌ ជានិយតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៤៧៨] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី

បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនេះផងចុះ ។

(៥៧៩) កុសលំ អនិយតំ ធម្មំ បដិច្ច កុសលោ អនិយតោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

(៥៨០) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារម្បិ បច្ចយវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកនិយតទុកំ និដ្ឋិតំ ។

## កុសលត្តិកសឧត្តរទុកំ

(៥៨១) កុសលំ សឧត្តរំ ធម្មំ បដិច្ច កុសលោ សឧត្តរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អកុសលំ សឧត្តរំ ធម្មំ បដិច្ច អកុសលោ សឧត្តរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អព្យាកតំ សឧត្តរំ ធម្មំ បដិច្ច អព្យាកតោ សឧត្តរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៨២) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៥៨៣) កុសលោ សឧត្តរោ ធម្មោ កុសលស្ស សឧត្តរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។

[៥៧៩] កុសលធម៌ ជាអនិយតៈ អាស្រ័យ នូវកុសលធម៌ ជាអនិយតៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

[៥៨០] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី បញ្ហាវារៈក្តី

បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនេះផងចុះ ។

ចប់ កុសលត្តិកនិយតទុកៈ ។

# កុសលត្តិកសឧត្តរទុកៈ

[៥៨១] កុសលធម៌ ប្រកបដោយឧត្តរៈ (ការកើតឡើងនូវខ្ពង់) អាស្រ័យ នូវកុសលធម៌ ប្រកបដោយឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អកុសលធម៌ ប្រកបដោយឧត្តរៈ អាស្រ័យ នូវអកុសលធម៌ ប្រកបដោយឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ ប្រកបដោយឧត្តរៈ អាស្រ័យ នូវអព្យាកតធម៌ ប្រកបដោយឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៥៨២] ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៥៨៣] កុសលធម៌ ប្រកបដោយឧត្តរៈ ជាបច្ច័យ នៃកុសលធម៌ ប្រកបដោយឧត្តរៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

អកុសលោ សឧត្តរោ ធម្មោ អកុសលស្ស សឧត្តរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ សឧត្តរោ ធម្មោ អព្យាកតស្ស សឧត្តរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៥៨៤) ហេតុយា សត្ត អារម្មណេ នវ អធិបតិយា នវ អវិគតេ តេរស ។

(៥៨៥) កុសលំ អនុត្តរំ ធម្មំ បដិច្ច កុសលោ អនុត្តរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អព្យាកតំ អនុត្តរំ ធម្មំ បដិច្ច អព្យាកតោ អនុត្តរោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៨៦) ហេតុយា ទ្វេ អារម្មណេ ទ្វេ អវិគតេ ទ្វេ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៥៨៧) កុសលោ អនុត្តរោ ធម្មោ កុសលស្ស អនុត្តរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អព្យាកតោ អនុត្តរោ ធម្មោ អព្យាកតស្ស អនុត្តរស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

អកុសលធម៌ ប្រកបដោយឧត្តរៈ ជាបច្ច័យ នៃអកុសលធម៌ ប្រកបដោយឧត្តរៈ ដោយហេតុប្បច្ច័យ មាន៣ៈ ៣ ។ អព្យាកតធម៌ ប្រកបដោយឧត្តរៈ ជាបច្ច័យ នៃអព្យាកតធម៌ ប្រកបដោយឧត្តរៈ ដោយហេតុប្បច្ច័យ ។

[៥៨៤] ក្នុងហេតុប្បច្ច័យ មាន៣ៈ ៧ ក្នុងអារម្មណប្បច្ច័យ មាន មាន៣ៈ ៩ ក្នុងអធិបតិប្បច្ច័យ មាន៣ៈ ៩ ក្នុងអវិគតប្បច្ច័យ មាន ៣ៈ ១៣ ។

[៥៨៥] កុសលធម៌ មិនមានឧត្តរៈ អាស្រ័យ នូវកុសលធម៌ មិនមានឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានឧត្តរៈ អាស្រ័យ នូវអព្យាកតធម៌ មិនមានឧត្តរៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៥៨៦] ក្នុងហេតុប្បច្ច័យ មាន៣ៈ ២ ក្នុងអារម្មណប្បច្ច័យ មាន៣ៈ ២ ក្នុងអវិគតប្បច្ច័យ មាន៣ៈ ២ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៥៨៧] កុសលធម៌ មិនមានឧត្តរៈ ជាបច្ច័យ នៃកុសលធម៌ មិនមានឧត្តរៈ ដោយហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានឧត្តរៈ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានឧត្តរៈ ដោយហេតុប្បច្ច័យ ។

(៥៨៨) អព្យាកតោ អនុត្តរោ ធម្មោ អព្យាកតស្ស អនុត្តរស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ អព្យាកតោ អនុត្តរោ ធម្មោ កុសលស្ស អនុត្តរស្ស ធម្មស្ស អារម្មណប្បច្ចយេន បច្ចយោ ។

(៥៨៩) ហេតុយា ទ្វេ អារម្មណេ ទ្វេ អធិបតិយា តីណិ អនន្តរេ ទ្វេ អវិគតេ ទ្វេ ។

យថា កុសលត្តិកេ បញ្ហាភេទម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកសឧត្តរទុកំ និដ្ឋិតំ ។

## កុសលត្តិកសរណទុកំ

(៥៩០) អកុសលំ សរណំ ធម្មំ បដិច្ច អកុសលោ សរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៩១) ហេតុយា ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៥៩២) កុសលំ អរណំ ធម្មំ បដិច្ច កុសលោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

[៥៨៨] អព្យាកតធម៌ មិនមានឧត្តរៈ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានឧត្តរៈ ដោយអារម្មណប្បច្ច័យ អព្យាកតធម៌ មិនមានឧត្តរៈ ជាបច្ច័យ នៃកុសលធម៌ មិនមានឧត្តរៈ ដោយអារម្មណប្បច្ច័យ ។

[៥៨៩] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអធិបតិប្បច្ច័យ មានវារៈ ៣ ក្នុងអនន្តរប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ២ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

ចប់ កុសលត្តិកសឧត្តរទុកៈ ។

## កុសលត្តិកសរណទុកៈ

[៥៩០] អកុសលធម៌ ប្រកបដោយរណៈ (លាមក) អាស្រ័យនូវអកុសលធម៌ ប្រកបដោយរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៥៩១] ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ ១ ។

[៥៩២] កុសលធម៌ មិនមានរណៈ អាស្រ័យនូវកុសលធម៌ មិនមានរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

អព្យាកតំ អរណំ ធម្មំ បដិច្ច អព្យាកតោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។ កុសលំ អរណញ្ច អព្យាកតំ អរណញ្ច ធម្មំ បដិច្ច អព្យាកតោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុបច្ចយា ។

(៥៩៣) កុសលំ អរណំ ធម្មំ បដិច្ច កុសលោ អរណោ ធម្មោ ឧប្បជ្ជតិ អារម្មណបច្ចយា ។ អព្យាកតំ អរណំ ធម្មំ បដិច្ច អព្យាកតោ អរណោ ធម្មោ ឧប្បជ្ជតិ អារម្មណបច្ចយា ។

(៥៩៤) ហេតុយា បញ្ច អារម្មណេ ទ្វេ អវិគតេ បញ្ច ។

សហជាតវារោបិ សម្បយុត្តវារោបិ

បដិច្ចវារសទិសា ។

(៥៩៥) កុសលោ អរណោ ធម្មោ កុសលស្ស អរណស្ស ធម្មស្ស ហេតុបច្ចយេន បច្ចយោ តីណិ ។ អព្យាកតោ អរណោ ធម្មោ អព្យាកតស្ស អរណស្ស ធម្មស្ស ហេតុបច្ចយេន បច្ចយោ ។

(៥៩៦) ហេតុយា ចត្តារិ អារម្មណេ ចត្តារិ អវិគតេ សត្ត ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

កុសលត្តិកសរណទុកំ និដ្ឋិតំ ។

អព្យាកតធម៌ មិនមានរណៈ អាស្រ័យ នូវអព្យាកតធម៌ មិនមានរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អព្យាកតធម៌ មិនមានរណៈ អាស្រ័យ នូវកុសលធម៌ មិនមានរណៈផង នូវអព្យាកតធម៌ មិនមានរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៥៩៣) កុសលធម៌ មិនមានរណៈ អាស្រ័យ នូវកុសលធម៌ មិនមានរណៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។ អព្យាកតធម៌ មិនមានរណៈ អាស្រ័យ នូវអព្យាកតធម៌ មិនមានរណៈ ទើបកើតឡើង ព្រោះអារម្មណប្បច្ច័យ ។

(៥៩៤) ក្នុងហេតុប្បច្ច័យ មានវារៈ ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៥៩៥) កុសលធម៌ មិនមានរណៈ ជាបច្ច័យ នៃកុសលធម៌ មិនមានរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អព្យាកតធម៌ មិនមានរណៈ ជាបច្ច័យ នៃអព្យាកតធម៌ មិនមានរណៈ ដោយហេតុប្បច្ច័យ ។

(៥៩៦) ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ៧ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

ចប់ កុសលត្តិកសរណទុកៈ ។

# វេទនាត្តិកសរណទុកំ

(៥៩៧) សុខាយ វេទនាយ សម្បយុត្តំ សរណំ ធម្មំ បដិច្ច សុខាយ វេទនាយ សម្បយុត្តោ សរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ ទុក្ខាយ វេទនាយសម្បយុត្តំ សរណំ ធម្មំ បដិច្ច ទុក្ខាយ វេទនាយសម្បយុត្តោ សរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ សរណំ ធម្មំ បដិច្ច អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ សរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៥៩៨) ហេតុយា តីណិ អវិគតេ តីណិ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៥៩៩) សុខាយ វេទនាយ សម្បយុត្តោ សរណោ ធម្មោ សុខាយ វេទនាយ សម្បយុត្តស្ស សរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ ទុក្ខាយ វេទនាយ សម្បយុត្តោ សរណោ ធម្មោ ទុក្ខាយ វេទនាយ សម្បយុត្តស្ស សរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

# វេទនាត្តិកសរណទុកៈ

(៥៩៧) ធម៌ ដែលសម្បយុត្តដោយសុខវេទនា ប្រកបដោយរណៈ អាស្រ័យ នូវធម៌ ដែលសម្បយុត្តដោយសុខវេទនា ប្រកបដោយរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ ដែលសម្បយុត្តដោយទុក្ខវេទនា ប្រកបដោយរណៈ អាស្រ័យ នូវធម៌ ដែលសម្បយុត្តដោយទុក្ខវេទនា ប្រកបដោយរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ ប្រកបដោយរណៈ អាស្រ័យ នូវធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ ប្រកបដោយរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៥៩៨) ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៥៩៩) ធម៌ ដែលសម្បយុត្តដោយសុខវេទនា ប្រកបដោយរណៈ ជាបច្ច័យ នៃធម៌ ដែលសម្បយុត្តដោយសុខវេទនា ប្រកបដោយរណៈ ដោយហេតុប្បច្ច័យ ។ ធម៌ ដែលសម្បយុត្តដោយទុក្ខវេទនា ប្រកបដោយរណៈ ជាបច្ច័យ នៃធម៌ ដែលសម្បយុត្តដោយទុក្ខវេទនា ប្រកបដោយរណៈ ដោយហេតុប្បច្ច័យ ។

អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ សរណោ ធម្មោ អទុក្ខមសុខាយ វេទនាយ សម្បយុត្តស្ស សរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(២០០) ហេតុយា តីណិ អារម្មណេ ឆ អវិគតេ តីណិ ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

(២០១) សុខាយ វេទនាយ សម្បយុត្តំ អរណំ ធម្មំ បដិច្ច សុខាយ វេទនាយ សម្បយុត្តោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ អរណំ ធម្មំ បដិច្ច អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(២០២) ហេតុយា ទ្វេ អារម្មណេ តីណិ អវិគតេ តីណិ ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(២០៣) សុខាយ វេទនាយ សម្បយុត្តោ អរណោ ធម្មោ សុខាយ វេទនាយ សម្បយុត្តស្ស អរណស្ស ធម្មស្ស

វេទនាត្តិកសរណទុកៈ

ធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ ប្រកបដោយរណៈ ជាបច្ច័យ នៃធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ ប្រកបដោយរណៈ ដោយហេតុប្បច្ច័យ ។

[ ៦០០ ] ក្នុងហេតុប្បច្ច័យ មានវារៈ ៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

[ ៦០១ ] ធម៌ ដែលសម្បយុត្តដោយសុខវេទនា មិនមានរណៈ អាស្រ័យ នូវធម៌ ដែលសម្បយុត្តដោយសុខវេទនា មិនមានរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ ធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ មិនមានរណៈ អាស្រ័យ នូវធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ មិនមានរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[ ៦០២ ] ក្នុងហេតុប្បច្ច័យ មានវារៈ ២ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[ ៦០៣ ] ធម៌ ដែលសម្បយុត្តដោយសុខវេទនា មិនមានរណៈ ជាបច្ច័យ នៃធម៌ ដែលសម្បយុត្តដោយសុខវេទនា មិនមានរណៈ

ហេតុប្បច្ចយេន បច្ចយោ ។ អទុក្ខមសុខាយ វេទ-នាយ សម្បយុត្តោ អរណោ ធម្មោ អទុក្ខមសុខា-យ វេទនាយ សម្បយុត្តស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

(៦០៤) ហេតុយា ទ្វេ អារម្មណេ ច អធិបតេ តីណិ ។

យថា កុសលត្តិកេ បញ្ហាវារស្មិំ ឯវំ វិត្ថារេតព្វំ ។

វេទនាត្តិកសរណទុកំ និដ្ឋិតំ ។

## វិបាកត្តិកសរណទុកំ

(៦០៥) វិបាកធម្មធម្មំ សរណំ ធម្មំ បដិច្ច វិបាក-ធម្មធម្មោ សរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៦០៦) ហេតុយា ឯកំ អធិបតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៦០៧) វិបាកំ អរណំ ធម្មំ បដិច្ច វិបាកោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ វិបាកធម្មធម្មំ អរណំ ធម្មំ បដិច្ច វិបាកធម្មធម្មោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

ដោយហេតុប្បច្ច័យ ។ ធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ មិនមានរណៈ ជាបច្ច័យ នៃធម៌ ដែលសម្បយុត្តដោយវេទនាមិនជាទុក្ខមិនជាសុខ មិនមានរណៈ ដោយហេតុប្បច្ច័យ ។

[៦០៤] ក្នុងហេតុប្បច្ច័យ មានវារៈ ៤ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

ចប់ វេទនាត្តិកសរណទុកៈ ។

## វិបាកត្តិកសរណទុកៈ

[៦០៥] ធម៌ មានវិបាកធម៌ជាប្រក្រតី ជាសរណៈ អាស្រ័យនូវធម៌ មានវិបាកធម៌ជាប្រក្រតី ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៦០៦] ក្នុងហេតុប្បច្ច័យ មានវារៈ១ ក្នុងអវិគតប្បច្ច័យ មានវារៈ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី បញ្ហាវារៈក្តី មានតែវារៈ១ ។

[៦០៧] វិបាកធម៌ ជាអរណៈ អាស្រ័យនូវវិបាកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មានវិបាកធម៌ជាប្រក្រតី ជាអរណៈ អាស្រ័យ នូវធម៌ មានវិបាកធម៌ជាប្រក្រតី ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

នេវវិបាកនវិបាកធម្មធម្មំ អរណំ ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ វិបាកំ អរណញ្ច នេវវិបាកនវិបាកធម្មធម្មំ អរណញ្ច ធម្មំ បដិច្ច វិបាកោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ វិបាកធម្មធម្មំ អរណញ្ច នេវវិបាកនវិបាកធម្មធម្មំ អរណញ្ច ធម្មំ បដិច្ច នេវវិបាកនវិបាកធម្មធម្មោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៦០៨) ហេតុយា តេរស អារម្មណេ បញ្ច អវិគតេ តេរស ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

(៦០៩) វិបាកោ អរណោ ធម្មោ វិបាកស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយា តីណិ ។ វិបាកធម្មធម្មោ អរណោ ធម្មោ វិបាកធម្មធម្មស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ នេវវិបាកនវិបាកធម្មធម្មោ អរណោ ធម្មោ នេវវិបាកនវិបាកធម្មធម្មស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។

ធម៌ មិនមែនជាវិបាកទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈ អាស្រ័យ នូវធម៌ មិនមែនជាវិបាកទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ វិបាកធម៌ ជាអរណៈ អាស្រ័យ នូវធម៌ ជាវិបាក ជាអរណៈផង មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាវិបាកទាំងមិនមែន មានវិបាកធម៌ជាប្រក្រតី ជាអរណៈ អាស្រ័យ នូវធម៌ មានវិបាកធម៌ ជាប្រក្រតី ជាអរណៈផង មិនមែនជាវិបាកទាំងមិនមែនមានវិបាកធម៌ជា ប្រក្រតី ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

[៦០៨] ក្នុងហេតុប្បច្ច័យ មានវារៈ ១៣ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៤ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

[៦០៩] វិបាកធម៌ ជាអរណៈ ជាបច្ច័យ នៃវិបាកធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មានវិបាកធម៌ជាប្រក្រតី ជាអរណៈ ជាបច្ច័យ នៃធម៌ មានវិបាកធម៌ជាប្រក្រតី ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ ធម៌ មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈ ជាបច្ច័យ នៃធម៌ មិនមែនជាវិបាកទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ជាអរណៈ ដោយហេតុប្បច្ច័យ ។

(៦១០) ហេតុយា សត្ត អារម្មណេ ឆ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

វិបាកត្តិកសរណទុកំ និដ្ឋិតំ ។

## ឧបាទិន្នត្តិកសរណទុកំ

(៦១១) អនុបាទិន្នុបាទានិយំ សរណំ ធម្មំ បដិច្ច អនុបាទិន្នុបាទានិយោ សរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៦១២) ហេតុយា ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៦១៣) ឧបាទិន្នុបាទានិយំ អរណំ ធម្មំ បដិច្ច ឧបាទិន្នុបាទានិយោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អនុបាទិន្នុបាទានិយំ អរណំ ធម្មំ បដិច្ច អនុបាទិន្នុបាទានិយោ អរណោ ធម្មោ

( ៦១០ ) ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៩ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្ដារ យ៉ាងនោះដែរ ។

ចប់ វិបាកត្តិកសរណទុកៈ ។

## ឧបាទិន្នត្តិកសរណទុកៈ

( ៦១១ ) អនុបាទិន្នុបាទានិយធម៌ (ធម៌ ដែលកម្មប្រកបដោយកិលេសមានតណ្ហាជាដើម មិនកាន់យកហើយតែជាប្រយោជន៍ដល់ឧបាទាន) ប្រកបដោយរណៈ អាស្រ័យ នូវអនុបាទិន្នុបាទានិយធម៌ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

( ៦១២ ) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

( ៦១៣ ) ឧបាទិន្នុបាទានិយធម៌ (ធម៌ ដែលកម្មប្រកបដោយកិលេសកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន) ជាអរណៈ (មិនមានកិលេស) អាស្រ័យ នូវឧបាទិន្នុបាទានិយធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អនុបាទិន្នុបាទានិយធម៌ ជាអរណៈ អាស្រ័យ នូវអនុបាទិន្នុបាទានិយធម៌ ជាអរណៈ

ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អនុបាទិន្នអនុបាទានិយំ អរណំ ធម្មំ បដិច្ច អនុបាទិន្នអនុបាទានិយោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។

(៦១៤) ហេតុយា នវ អារម្មណេ តីណិ អវិគតេ នវ ។

សហជាតវារេបិ សម្បយុត្តវារេបិ បដិច្ចវារសទិសា ។

(៦១៥) ឧបាទិន្នុបាទានិយោ អរណោ ធម្មោ ឧបាទិន្នុបាទានិយស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។ អនុបាទិន្នុបាទានិយោ អរណោ ធម្មោ អនុបាទិន្នុបាទានិយស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អនុបាទិន្នអនុបាទានិយោ អរណោ ធម្មោ អនុបាទិន្នអនុបាទានិយស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។

(៦១៦) ហេតុយា សត្ត អារម្មណេ ឆ អវិគតេ តេរស ។

យថា កុសលត្តិកេ បញ្ហាវារម្បិ ឯវំ វិត្ថារេតព្វំ ។

ឧបាទិន្នត្តិកសរណទុកំ និដ្ឋិតំ ។

ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អនុប្បាទិន្នអនុប្បាទា-និយធម៌ ជាអរណៈ អាស្រ័យ នូវអនុប្បាទិន្នអនុប្បាទានិយធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។

( ៦១៤ ) ក្នុងហេតុប្បច្ច័យ មានវារៈ ៩ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៣ ក្នុងអវិគតប្បច្ច័យ មានវារៈ ៩ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

( ៦១៥ ) ឧប្បាទិន្នុប្បាទានិយធម៌ ជាអរណៈ ជាបច្ច័យ នៃឧប្បាទិន្នុប្បាទានិយធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។ អនុប្បាទិន្នុប្បាទានិយធម៌ ជាអរណៈ ជាបច្ច័យ នៃអនុប្បាទិន្នុប្បាទានិយ-ធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ ។ អនុប្បាទិន្នអនុប្បាទានិយ-ធម៌ ជាអរណៈ ជាបច្ច័យ នៃអនុប្បាទិន្នអនុប្បាទានិយធម៌ ជាអរណៈ ដោយហេតុប្បច្ច័យ មានវារៈ ៣ ។

( ៦១៦ ) ក្នុងហេតុប្បច្ច័យ មានវារៈ ៧ ក្នុងអារម្មណប្បច្ច័យ មានវារៈ ៦ ក្នុងអវិគតប្បច្ច័យ មានវារៈ ១៣ ។

ឯបញ្ហាវារៈ ក្នុងកុសលត្តិកៈ យ៉ាងណា
បណ្ឌិត គប្បីឲ្យពិស្តារ យ៉ាងនោះចុះ ។

ចប់ ឧប្បាទិន្នត្តិកសរណទុកៈ ។

# សង្កិលិដ្ឋត្តិកសរណទុកំ

(៦១៧) សង្កិលិដ្ឋសង្កិលេសិកំ សរណំ ធម្មំ បដិច្ច សង្កិលិដ្ឋសង្កិលេសិកោ សរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៦១៨) ហេតុយា ឯកំ អវិគតេ ឯកំ ។

សហជាតវារេបិ បញ្ហាវារេបិ សព្វត្ថ ឯកំ ។

(៦១៩) អសង្កិលិដ្ឋសង្កិលេសិកំ អរណំ ធម្មំ បដិច្ច អសង្កិលិដ្ឋសង្កិលេសិកោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។ អសង្កិលិដ្ឋអសង្កិលេសិកំ អរណំ ធម្មំ បដិច្ច អសង្កិលិដ្ឋអសង្កិលេសិកោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា តីណិ ។ អសង្កិលិដ្ឋសង្កិលេសិកំ អរណញ្ច អសង្កិលិដ្ឋអសង្កិលេសិកំ អរណញ្ច ធម្មំ បដិច្ច អសង្កិលិដ្ឋសង្កិលេសិកោ អរណោ ធម្មោ ឧប្បជ្ជតិ ហេតុប្បច្ចយា ។

(៦២០) ហេតុយា បញ្ច អារម្មណេ ទ្វេ អវិគតេ បញ្ច ។

សហជាតវារេបិ សម្បយុត្តវារេបិ

បដិច្ចវារសទិសា ។

# សង្កិលិដ្ឋត្តិកសរណទុកៈ

(៦១៧) សង្កិលិដ្ឋសង្កិលេសិកធម៌ (ធម៌ ដែលសៅហ្មងទាំង គួរដល់សេចក្តីសៅហ្មង) ជាសរណៈ អាស្រ័យ នូវសង្កិលិដ្ឋសង្កិលេសិកធម៌ ជាសរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៦១៨) ក្នុងហេតុប្បច្ច័យ មានវារៈ ១ ក្នុងអវិគតប្បច្ច័យ មានវារៈ ១ ។

ក្នុងបច្ច័យទាំងអស់ ក្នុងសហជាតវារៈក្តី
បញ្ហាវារៈក្តី សុទ្ធតែមានវារៈ ១ ។

(៦១៩) អសង្កិលិដ្ឋសង្កិលេសិកធម៌ (ធម៌ ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង) ជាអរណៈ អាស្រ័យ នូវអសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។ អសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាអរណៈ អាស្រ័យ នូវអសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាអរណៈ ទើបកើតឡើង ព្រោះហេតុប្បច្ច័យ មានវារៈ ៣ ។ អសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈ អាស្រ័យ នូវអសង្កិលិដ្ឋសង្កិលេសិកធម៌ ជាអរណៈផង នូវអសង្កិលិដ្ឋអសង្កិលេសិកធម៌ ជាអរណៈផង ទើបកើតឡើង ព្រោះហេតុប្បច្ច័យ ។

(៦២០) ក្នុងហេតុប្បច្ច័យ មានវារៈ៥ ក្នុងអារម្មណប្បច្ច័យ មានវារៈ ២ ក្នុងអវិគតប្បច្ច័យ មានវារៈ ៥ ។

សហជាតវារៈក្តី សម្បយុត្តវារៈក្តី ដូចគ្នានឹងបដិច្ចវារៈដែរ ។

(៦២១) អសង្កិលិដ្ឋសង្កិលេសិកោ អរណោ ធម្មោ អសង្កិលិដ្ឋសង្កិលេសិកស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ ។ អសង្កិដ្ឋអសង្កិលេសិកោ អរណោ ធម្មោ អសង្កិលិដ្ឋអសង្កិលេសិកស្ស អរណស្ស ធម្មស្ស ហេតុប្បច្ចយេន បច្ចយោ តីណិ ។

(៦២២) ហេតុយា ចត្តារិ អារម្មណេ តីណិ អវិគតេ សត្ត ។

យថា កុសលត្តិកេ បញ្ហាវិភង្គោ ឯវំ វិត្ថារេតព្វំ ។

សង្កិលិដ្ឋត្តិកសរណទុកំ និដ្ឋិតំ ។

## វិតក្កត្តិកសរណទុកំ

